# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែមេសា ឆ្នាំទី៤ ថ្ងៃទី០១-៣១ ខែឧសភា ឆ្នាំ២០១១ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ

លេខ ៤៥

Formation, Dialogue, Cooperation

## មាតិកា



យុវជនចាប់ផ្ដើម
អាជីវកម្មដោយ...
ទំព័រ ៥



តើការអភិរក្សមាន
អត្ថន័យ និង...
ទំព័រ ៩



គីកេ : “ព្រះជាម្ចាស់
មិនត្រូវការ...”
ទំព័រ ១៤

# ភាពក្រីក្រ និងប្រពៃណី គឺជាកត្តា សំខាន់ជំរុញឱ្យមានពលកម្មកុមារ



នៅប្រទេសកម្ពុជា កុមារដែលកំពុងធ្វើពលកម្មមានចំនួន ៧៥០០០០នាក់ ហើយកុមារដែលស្ថិតនៅក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរទៀតសោតគឺមានរហូតដល់ ២៥០០០០នាក់។ នេះបើតាមការសិក្សាមួយដែលឧបត្ថម្ភដោយអង្គការពលកម្មអន្តជាតិកាលពីឆ្នាំ២០០១។ តើអ្វីខ្លះគឺជាកត្តាជំរុញឱ្យកុមារទាំងនោះងាកទៅធ្វើពលកម្មដើម្បីចិញ្ចឹមជីវិត ជំនួសឱ្យការទៅសិក្សារៀនសូត្រដើម្បីអនាគតវិញនោះ ? ទំព័រទី១០_១១




## អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : **FM 102.5 Mhz** ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: **FM 102.5 Mhz** ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : **FM 107.5 Mhz** ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : **FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ *(សកម្មភាពជនភៀសសឹកកាលពីខែមុន ពេលនេះពួកគាត់វិលទៅផ្ទះវិញហើយ)*



Photo : S. Philong

គ្រាន់តែការប្រយុទ្ធបានចាប់ផ្តើមរយៈពេលបីថ្ងៃគឺចាប់ពីថ្ងៃទី២២ មេសា មានប្រជាជនភៀសខ្លួនខ្មែរប្រមាណ ១៨០០០នាក់ បានចាកចេញពីលំនៅដ្ឋានដើម្បីរកកន្លែងមានសុវត្ថិភាព។



Photo : Philong

ជំរំភៀសសឹកទាំង ៧កន្លែងត្រូវបានរៀបចំឡើងដើម្បីទទួលជនភៀសខ្លួនកម្ពុជានៅខេត្តឧត្តរមានជ័យ ដោយសារតែលំនៅដ្ឋានរបស់ពួកគាត់មួយចំនួនត្រូវបានគ្រាប់ផ្លោងថៃធ្លាក់ត្រូវ និងធ្វើឱ្យខូចខាតក្នុងអំឡុងពេលប្រយុទ្ធគ្នា។



Photo : Philong

ប្រជាជនភៀសសឹកកម្ពុជាជាច្រើនពាន់គ្រួសារបានវិលទៅកាន់លំនៅ-ដ្ឋានវិញ បន្ទាប់ពីការប្រយុទ្ធបានស្ងប់ស្ងាត់ចាប់ពីថ្ងៃទីបី ខែឧសភា។



Photo : Philong

កាកបាទក្រហមកម្ពុជា និងមន្ត្រីអាជ្ញាធរពាក់ព័ន្ធ ក្នុងកិច្ចខិតខំយកចិត្តទុកដាក់ផ្តល់ស្បៀងដើម្បីជួយសម្រាលទុក្ខលំបាកជនភៀសសឹក។



Photo : S. Philong

ប្រជាជនជនភៀសសឹកមានសុខភាពល្អធម្មតា នៅពេលភៀសខ្លួន ដោយមានក្រុមវេជ្ជបណ្ឌិត និងពេទ្យចល័តនៅទីនោះ ចាំថែរក្សា។

# សម្ដេចប៉ាប យ៉ូហាន ប៉ូលទី ២ ជាអ្នកមានសុភមង្គលពេញលក្ខណៈ

មនុស្សប្រមាណជា១,៥ លាននាក់ មានលោកកាឌីណាល់ អភិបាល បព្វជិត បព្វជិតា អ្នកមុខ អ្នកការ ប្រមុខរដ្ឋ និងគ្រីស្តបរិស័ទ មកពីគ្រប់ទីកន្លែង ក្នុងពិភពលោកបានចូលរួមក្នុងពិធីប្រកាសសម្តេចប៉ាប យ៉ូហាន ប៉ូល ទី២ ជាអ្នកមានសុភមង្គលពេញលក្ខណៈ ក្រោមអធិបតីរបស់សម្តេចប៉ាប បេណេឌីកតូទី ១៦ កាលពីថ្ងៃទី១ ខែឧសភាកន្លងទៅ នៅក្នុងទីធ្លាវិសាលវិហារសន្តសិលានៃទីក្រុងរ៉ូម បុរីវ៉ាទីកង់។ នេះបើតាមប្រសាសន៍របស់លោក អូលីវីយេ អភិបាលព្រះសហគមន៍ភូមិភ្នំពេញ។ តំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលបានចូលរួម មានលោកអភិបាលសុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ លោកម៉ារីយ៉ូ ហ្គេហ្សិ លោកប្រ៊ុយណូ កូសមី និងលោកបូជាចារ្យអ៊ុន សុន។

លោកអភិបាលអូលីយេ បានរៀបរាប់បន្តថា យប់មុនថ្ងៃពិធីប្រជាជនជួបជុំគ្នា អធិដ្ឋានតាមព្រះមាលា (ផ្កាំ) ដែលសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ បានបន្ថែមអំពីទំនាក់ទំនងនឹងព្រះពន្លឺ និងមានការផ្តល់សក្ខីភាព ពីសំណាក់អ្នកនាំពាក្យ និងលេខាផ្ទាល់របស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២ ព្រមទាំងសក្ខីភាពអំពីការអស្ចារ្យរបស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២ គឺបងស្រីម្នាក់ដែលបានជាពីជំងឺដោយការអធិដ្ឋាន អង្វរសម្តេចប៉ាប យ៉ូហាន ប៉ូលទី២។ លោកបន្តថានៅយប់នេះ មានប្រជាជន ២៥ ម៉ឺននាក់បន្តការអធិដ្ឋានរហូតភ្លឺ។

ចំពោះអត្ថន័យរបស់ពិធីបុណ្យនេះ លោកក៏បន្តថា នេះជាដំណាក់កាលចុងក្រោយ មុននឹងប្រកាសថាសម្តេចប៉ាបយ៉ូហានប៉ូលទី២ ជាសន្តបុគ្គលមួយរូប។

លោកអភិបាលរំឭកថា នៅពេលសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ បានទទួលមរណភាពប្រជាជនប្រមាណជា ២លាននាក់ចូលរួម ស្រែកខ្លាំងៗ ថា សូមឱ្យតែងតាំងទៅជាសន្តបុគ្គលឆាប់ៗឡើង។ ដូច្នេះ សម្តេចប៉ាបបេណេឌីកតូទី១៦ អនុញ្ញាតឱ្យមានការអង្កេតមិនចាំយូរឡើយ ដែលធម្មតាគេត្រូវចាំ៥ឆ្នាំ។ ការអង្កេតធ្វើឡើងនៅភូមិរ៉ូមនិងភូមិភាគដើមរបស់គាត់នៅប្រទេសប៉ូឡូញ។ គេបានធ្វើចប់ ហើយក៏ផ្ញើទៅក្រសួងសន្តសន្តីនៅក្រុងរ៉ូមដើម្បីពិនិត្យវាយតម្លៃ។ មានការអស្ចារ្យមួយដែលគេទទួលស្គាល់ បងស្រីម្នាក់បានជាពីជំងឺដោយសាររូបគាត់អធិដ្ឋានអង្វរសម្តេចប៉ាប យ៉ូហាន ទី២ ដែលគ្រូពេទ្យមិនអាចពន្យល់បានព្រោះជាជំងឺធ្ងន់ធ្ងរ។ ក្រោយពីបានការទទួលស្គាល់នូវការណ៍អស្ចារ្យនេះ គេប្រកាសទទួលស្គាល់ថា សម្តេចប៉ាបយ៉ូហានប៉ូលទី២ ជាអ្នកមានសុភមង្គលពេញលក្ខណៈ។



Photo : DR



Photo : DR

លោកអភិបាលអូលីវីយេបញ្ជាក់ថា ពិធីនេះនាំឱ្យយើងមានអំណរសប្បាយជាពិសេសនាំឱ្យយើងមានកម្លាំងសាជាថ្មី និងភ្ញាក់ស្មារតី ដោយយកសម្តេចប៉ាបយ៉ូហានប៉ូលទី២ ជាគំរូ អង្វរសម្តេចប៉ាប នឹងឱ្យយើងមានជំនឿថែមទៀតពីព្រោះថាពេញមួយជីវិតជាសម្តេចប៉ាប លោកទទួលជោគជ័យពិតមែនដោយសារជំនឿរបស់គាត់។ ដោយសារការអធិដ្ឋាន គាត់បានជិតស្និទ្ធជាមួយនិងព្រះយេស៊ូ។ គ្រប់ពេលគាត់អធិដ្ឋានដល់ព្រះយេស៊ូ និងដល់ព្រះនាងម៉ារីដែរ។

លោកអភិបាលសង្ឃឹមថា អ្វីដែលព្រះសហគមន៍បានធ្វើនៅប្រទេសកម្ពុជាតាមរយៈខិតបណ្ណផ្ទាំងគំនូរសម្តេចប៉ាប សៀវភៅ និងភាពយន្តនាំឱ្យគ្រីស្តបរិ-ស័ទស្គាល់សម្តេចប៉ាប យ៉ូហាន ប៉ូល ទី២ ថែមទៀត ដោយមិនត្រឹមតែស្គាល់ពីជីវិតតែស្គាល់ដោយស៊ីជម្រៅអំពីចិត្តគំនិតរបស់គាត់។ លោកអភិបាលរំឭកថា ពេលសម្តេចប៉ាបយ៉ូហានប៉ូលទី២ ទទួលមុខងារជាសម្តេចប៉ាប លោកបានមានប្រសាសន៍ថា: "ចូរកុំខ្លាចអី! ចូរបើកទ្វារទទួលព្រះយេស៊ូក្នុងគ្រប់ទីកន្លែងក្នុងវប្បធម៌ និងសេដ្ឋកិច្ច..."។ នេះគឺណែនាំជីវិតយើង។ អ្វីៗ ទាំងអស់ដែលលោកបាន ធ្វើដើម្បីព្រះយេស៊ូ អ្វីៗទាំងអស់ដើម្បីប្រកាសដំណឹងល្អ។ សម្តេចប៉ាប យ៉ូហាន ប៉ូល ទី២ គឺជាទូតនៃសន្តិភាព ទូតរបស់ព្រះយេស៊ូ ទូតនៃសេចក្តីពិត និងទូតនៃដំណឹងល្អ។

សម្រាប់លោកអភិបាលផ្ទាល់ លោកបានយកសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ ជាគំរូសម្រាប់ជីវិតជាគ្រីស្តបរិស័ទ និងជីវិតនៃការត្រាស់ហៅតាំងពីលោកនៅវ័យក្មេង។ រយៈពេល ២៧ឆ្នាំ លោករៀនច្រើនអំពីបទពិសោធន៍របស់យ៉ូហាន ប៉ូលទី២។ លោកអភិបាលបានរៀបរាប់សកម្មភាពរបស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២ថា លោកបានធ្វើដំណើរចេញទៅក្រៅ ១០៤ដង សួរសុខទុក្ខប្រជាជនចំនួន ១២៩ប្រទេសក្នុងទ្វីបទាំងអស់។ លោកបង្កើតនូវទិវាយុវជនពិភពលោកនៅ១៩៨៥។ លោកនាំឱ្យយុវជនមានជំនឿ និងមានសេចក្តីសង្ឃឹម។ លោកធ្វើឱ្យសាសនាទាំងអស់ជួបជុំគ្នា មានទំនាក់ទំនងល្អនឹងគ្នាព្រមទាំងធ្វើឱ្យប្រទេសកុម្មុយនីស្តមួយចំនួនកែប្រែ។ លោកក៏ជាទូតនៃសន្តិភាព។ ក្នុងមួយជីវិតរបស់លោក លោកនាំឱ្យគេមានការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស ឱ្យមនុស្សជាតិយល់ថា ជីវិតមានតម្លៃ និងមានសេចក្តីថ្លៃថ្នូរពិតប្រាកដ។ លោកប្រឆាំងយ៉ាងខ្លាំង និងការពន្យាកំណើត និងការពន្លូតកូន។

**លី សុវណ្ណា**

## សេដ្ឋកិច្ច

# កម្ពុជាពង្រីកផ្ទៃដីដាំកៅស៊ូបាន ៣៩,៦%

**ខាន់ ភីរម្យ**

មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងឱ្យដឹងថា កាលពីឆ្នាំ២០១០កម្ពុជាបាន ពង្រីកផ្ទៃដីដាំកៅស៊ូបានប្រមាណជា ៣៩,៦% បើ ប្រៀបធៀបនឹងឆ្នាំ២០០៩។

លោកគិត សេង អនុរដ្ឋលេខាធិការនៅក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងនៅ ក្នុងសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថាសន្ទុះនៃការដាំដើមកៅស៊ូនៅកម្ពុជា មានការកើនឡើងជាលំដាប់ដោយសារតម្លៃកៅស៊ូ មានការកើនឡើងខ្ពស់គួបផ្សំនឹងស្ថានភាពនយោ-បាយសន្តិសុខល្អប្រសើរ ហើយនិងការអនុវត្តគោល នយោបាយសេរីភាវូបនីយកម្មសម្រាប់ការលក់ដូរ ផលិតផលកៅស៊ូគ្រួសារនៅក្នុងស្រុក។

លោកបានបញ្ជាក់ថា: "ផ្ទៃដីដាំដំណាំកៅស៊ូនៅ កម្ពុជា កើនឡើងពី១២៨៩២០ ហិចតា ឆ្នាំ២០០៩ ទៅដល់១៨១៤៣០ហិចតាឆ្នាំ២០១០"។ លោកក៏ បានឱ្យដឹងថា សព្វថ្ងៃនេះ ផ្ទៃដីចំការកៅស៊ូដែល មានស្រាប់ មាន ៤៧០៩២ហិចតា។ ផ្ទៃដីវិនិយោគ ថ្មី ស្ថិតនៅក្រោមសម្បទានដីសេដ្ឋកិច្ច មានចំនួន ៥២៥២៨ហិចតា ហើយផ្ទៃដីចំការកៅស៊ូគ្រួសារ គឺ មាន៨១,៨១៣ហិចតា។ លោកបន្តថាដោយសារ


Photo : S. Philong

តែគោលនយោបាយទាក់ទាញវិនិយោគទុន វិស័យ កៅស៊ូលើដីសម្បទានសេដ្ឋកិច្ច មានការកើនឡើង រហូតដល់ប្រមាណជា១៣៥%ឯណោះ។ ចំណែកឯ ចំការកៅស៊ូគ្រួសារ ក៏មានការកើនឡើង ប្រមាណ ៣៤,៨% ដែរ។

សូមបញ្ជាក់ថាទីផ្សារកៅស៊ូនៅទីក្រុងហូជីមិញ ប្រទេសវៀតណាមកាលពីដើមខែមេសា មានតម្លៃ កៅស៊ូបានកើនឡើង រហូតដល់ ៥៤០០ដុល្លារ ក្នុង មួយតោន ខណៈដែលកាលពីឆ្នាំទៅ មានតម្លៃត្រឹម តែ ២៥០០ដុល្លារក្នុងមួយតោនប៉ុណ្ណោះ។

លោកម៉ក់ គឹមហុង ប្រធានសមាគមចំការកៅ-ស៊ូកម្ពុជា បានអះអាងប្រាប់ អ្នកសារព័ត៌មានកាល ពីដើមខែមេសា មុននេះ ថា តម្លៃកៅស៊ូនៅកម្ពុជា ក្នុងឆ្នាំ២០១១នេះ ឋិតនៅចន្លោះ ពី៤៥០០ ដុល្លារ ទៅដល់៥៥០០ដុល្លារ ក្នុងមួយតោន។

កាលពីនៅឆ្នាំ២០១០ ផលិតផលកៅស៊ូដែលជា ដំណាំកសិឧស្សាហកម្ម និងត្រូវបានគេចាត់ទុកថា ជាដំណាំមាសសមួយនៃប្រទេសកម្ពុជាមានទីផ្សារ នៅឯប្រទេសវៀតណាម ចិន ឬប្រទេសកូរ៉េខាង ត្បូងជាដើម។ ប៉ុន្តែ នៅដើមឆ្នាំនេះ គេឃើញមាន ការបញ្ជាទិញផលិតផលកៅស៊ូរបស់កម្ពុជាពីស-ភាព អឺរ៉ុបតាមរយៈប្រទេសសិង្ហបុរី។

### តម្លៃនៃការនាំចេញកៅស៊ូមាន រហូតដល់ ៨៧លានដុល្លារ

**បើយោងតាមតួលេខរបស់ក្រសួងពាណិជ្ជ-កម្ម បានឱ្យដឹងថា នៅឆ្នាំ២០១០ កន្លងទៅនេះ កម្ពុជាបាននាំចេញកៅស៊ូទៅកាន់ទីផ្សារក្រៅ ប្រទេស មានតម្លៃប្រមាណ៨៧លានដុល្លារ។**

**ប្រភពដដែលនោះបានឱ្យដឹងថា បរិមាណ នេះ គឺនៅទាបទេ បើប្រៀបធៀបនឹងផលិត ផលពីវិស័យកាត់ដេរ។ ប៉ុន្តែបើប្រៀបធៀបទៅ នឹងផលិតផលកសិកម្ម ដែលនាំចេញផ្សេងៗ ទៀត គឺថាខ្ពស់ដែរ។**

**បើតាមរបាយការណ៍បូកសរុបប្រចាំឆ្នាំរបស់ ក្រសួងវិញ ក៏ឱ្យបានឱ្យដឹងថា បរិមាណនៃការ នាំចេញកៅស្វ គឺមានតម្លៃ ៨៧លានដុល្លារ ខណៈដែលការនាំចេញអង្ករ គឺមានតម្លៃត្រឹមតែ ៣៥លានដុល្លារ សណ្តែកសៀង ១១លានដុល្លារ និងដំឡូងមីមាន៤លានដុល្លារនោះ។**

## សុខភាព

# អាកាសធាតុប្រែប្រួលធ្វើឱ្យសុខភាពជួបបញ្ហាជំងឺផ្លូវដង្ហើមច្រើន

**ជាត សំភី**

នាពេលសព្វថ្ងៃនេះ បញ្ហាបរិស្ថានកាន់តែធ្វើឱ្យ ជះឥទ្ធិពលខ្លាំងឡើងៗ ទៅដល់សុខភាពមនុស្ស។ អាកាសធាតុដែលតែងប្រែប្រួលពីក្តៅមកត្រជាក់ ពីត្រជាក់មក ក្តៅតែងតែនាំមកនូវជំងឺផ្សេងៗ ជា ពិសេសជំងឺទាក់ទងនិងផ្លូវដង្ហើម។

បើយោងតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ហែម សុខហាន នៃមន្ទីរពេទ្យកុមារជាតិ បានឱ្យដឹង ថា នៅពេលអាកាសធាតុប្រែប្រួល ជាពិសេស នៅ ពេលប្រែប្រួលពីក្តៅមកត្រជាក់ធ្វើឱ្យពពួកវីរុសរីក លូតលាស់ដូចជាពពួកវីរុសជំងឺផ្តាសាយ។ នៅពេល មនុស្សម្នាក់មានជំងឺផ្តាសាយ គាត់មានអាការៈដូច ជាឈឺក្បាល ឬហៀរសំបោរ។ នៅពេលនោះធ្វើឱ្យ


Photo : Vanith-Philong

ភាពស៊ាំគាត់ទន់ខ្សោយ ដែលធ្វើឱ្យមានការជ្រៀត ចូលរបស់ពពួកបាក់តេរីផ្សេងៗ។ លោកវេជ្ជបណ្ឌិត ហែម សុខហាន មានប្រសាសន៍បន្តថា បាក់តេរីទាំង នោះភាគច្រើនធ្វើឱ្យអ្នកជំងឺមានជំងឺរលាកទងសួត ឬជំងឺសួត...។ នៅពេលនោះអ្នកជំងឺគាត់ក្អក។ អ្នក ជំងឺមួយចំនួនមិនបានទៅព្យាបាលបែរជាទៅឱ្យគេ ផ្សំថ្នាំក្អកឱ្យដែលធ្វើឱ្យអាការៈកាន់តែធ្ងន់ធ្ងរ និង ធ្វើឱ្យមានស្លេស្មនៅក្នុងសួត ដែលអាចនាំឱ្យគ្រោះ ថ្នាក់ដល់ជីវិត បើមិនបានព្យាបាលទាន់ពេល។

បើក្នុងករណីមានក្អក អ្នកជំងឺមិនគួរឱ្យគេផ្សំថ្នាំ ដោយខ្លួនឯងលេបឡើយ ពោលគឺត្រូវទៅរកវេជ្ជ-បណ្ឌិតជំនាញដើម្បីទទួលការព្យាបាលជាបន្ទាន់។

លោកវេជ្ជបណ្ឌិតហែម សុខហាន មានប្រសាសន៍ ថា នៅពេលអាកាសធាតុប្រែប្រួលដូច្នេះ ការរស់ នៅឱ្យមានអនាម័យ គឺជាអ្វីដែលចាំបាច់ត្រូវតែធ្វើ ដូចជាការលាងដៃជាប់ជាប្រចាំ និងហាមខាកស្តោះ ពាសវាលពាសកាលជាដើម។ បើមានអាការៈមិន ស្រួលខ្លួន សូមប្រជាជនទៅរកពេទ្យជំនាញ ដើម្បី ព្យាបាលដោយកុំផ្សំថ្នាំលេបផ្តេសផ្តាស។



Photo : V. Sambath

# យុវជនចាប់ផ្ដើមអាជីវកម្មដោយខ្លួនឯង គឺជាជម្រើសមួយ

**ខាន់ ភីរម្យ**

បណ្ដាយុវជនដែលកំពុងប្រកបរបរខ្លួនឯង បានអះអាង ការចាប់ផ្ដើមអាជីវកម្មដោយខ្លួនឯង គឺជាជម្រើសមួយដ៏ប្រសើរ ដែលអាចនឹងស្វែងរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបាន។

យុវជនជី មករា អ្នកប្រកបរបរជាជាងជួសជុលម៉ូតូ បានអះអាងថា ជាមួយនឹងអាជីព ជាជាងម៉ូតូនេះ ខ្លួនគេអាចនឹងស្វែងរកនូវប្រាក់ចំណូលល្មមនឹងរស់នៅ ហើយអាចនឹងសល់ប្រាក់ សម្រាប់យកទៅបង្កបង្កើតគ្រួសារបាន។

បើតាមការអះអាងរបស់មករាក្នុងមួយថ្ងៃ ក្នុងរបរជាងជួសជុលម៉ូតូនេះ គេអាចរកប្រាក់ចំណូលពី១00000រៀល ទៅដល់២00,000រៀលហើយ កាត់ថ្លៃគ្រឿងបន្លាស់ និងថ្លៃបាយទឹកទៅ គេអាចសល់មធ្យមក៏៤0000ទៅ ៥0000រៀលដែរនៅក្នុងមួយថ្ងៃ។ មករាបានឱ្យដឹងថា ជាមួយនឹងប្រាក់ចំណូលនេះ គេគឺអាចសល់ប្រាក់បានខ្លះ ហើយទើបតែអាចរៀបការបានភរិយាមួយ កាលពីខែមីនាមុនទៅនេះ។មករាបានបញ្ជាក់ឱ្យដឹងដែរថា: "របរនេះប្រឡាក់បន្តិច តែខ្ញុំអាចរកលុយបានល្មម អាចផ្ដល់សុភមង្គលគ្រួសារខ្ញុំបាន"។

នេះគឺជាជោគជ័យមួយរបស់យុវជនមួយរូប។ ប៉ុន្តែក្រឡេកមើលទៅមើលយុវជនម្នាក់ទៀតមានឈ្មោះម៉ៅ បូរ៉ា ក៏អាចចាត់ទុកថា រូបគេក៏កំពុងតែច្នៃប្រឌិតមុខរបរផ្ទាល់ខ្លួនមួយដែរ ដោយសារគេបានតុបតែងខ្លួនស្អាតប្លែក ហើយប្រកាសលក់ជ្រក់និងម៉ាំល្ហុងនៅតាមដងផ្លូវ។

យុវជនម៉ៅ បូរ៉ាដែលមានអាយុ២៥ឆ្នាំ និងមកពីភូមិ ពេជ្រផ្សារ ស្រុកកោះអណ្ដែត ខេត្តតាកែវ បានអះអាងទាំងសម្លៀកបំពាក់តឺនុយ អាវធំ ពាក់ក្រវ៉ាត់ក ស្បែកជើងប៊ូ នៅពេលគេកំពុងតែពពាយនាយលក់ជ្រក់ថា ជាមួយនឹងការតុបតែងខ្លួនបែបនេះក្នុងមួយថ្ងៃ រូបគេគឺអាចនឹងលក់ជ្រក់ស្ពៃក្ដោបអស់ ៥0គីឡូក្រាម និងម៉ាំល្ហុង ៤គីឡូក្រាម ជាមួយនឹងប្រាក់ចំណូលទាំងដើម ទាំងចុងជិត ២00 000 រៀលក្នុងមួយថ្ងៃ។

ជារៀងរាល់ថ្ងៃ បូរ៉ាតែងពពាយនាយលក់ជ្រក់និងម៉ាំជាមួយនិងសម្លៀកបំពាក់ខុសប្លែកពីអ្នកលក់ផ្សេងៗទៀតនៅតាមច្រកកន្លុកកន្លៀត ដែលលាតសន្ធឹងពីសង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ ទៅដល់តំបន់បាបារាំង នៅម្ដុំមុខព្រះបរមរាជវាំង។

បូរ៉ាបានឱ្យដឹងថា ពេលមកភ្នំពេញដំបូង កាលពីឆ្នាំ២00៩ គេមិនមែនជាអ្នកជ្រក់បែបនេះទេ។ រូបគេប្រកបរបរជាអ្នកលក់ចាប់ហួយដោយចុះទៅទិញទំនិញនៅព្រំដែនវៀតណាម មកបោះលក់នៅតាមផ្សារនៅក្នុងទីក្រុងភ្នំពេញ។ ប៉ុន្តែរបរនេះមិនសូវកាក់កប ក៏មកលក់ជ្រក់ ប៉ុន្តែក៏មិនសូវកាក់កបទៀត ជាហេតុធ្វើឱ្យគេបែកគំនិតកែច្នៃជាអ្នកលក់ជ្រក់ និងម៉ាំល្ហុងបែបនេះទៅ។

ជាមួយនិងមុខរបរនេះ បូរ៉ាដែលបានបញ្ចប់ការសិក្សាត្រឹមតែបឋមសិក្សា គឺអាចនឹងរកស៊ីចិញ្ចឹមប្រពន្ធ និងកូនមួយ បាននៅក្នុងជីវភាពមួយប្រសើរ ក្រោយពីបានចាកចេញពីស្រុកកំណើត។ បូរ៉ាបានឱ្យដឹងថា ការតុបតែងខ្លួនបែបនេះគឺដំបូងចេញមកពីការចំអែចំអន់លេងរបស់អ្នកលក់ៗដូចគ្នា។ ប៉ុន្តែក្រោយពីការអនុវត្តជាក់ស្ដែង ក៏បានធ្វើឱ្យមុខរបររបស់បូរ៉ាកំពុងតែទទួលបានជោគជ័យ និងបានការគាំទ្រ។ លោកបានបញ្ជាក់ថា: "កាលដំបូង គឺរៀងអៀនៗដែរ ហើយខ្លះគេថា ខ្ញុំឆ្កួត តែឥឡូវទម្លាប់ហើយ។ ហើយនៅថ្ងៃខ្លះនោះ ខ្ញុំគ្រាន់តែភ្លេចពាក់ក្រវ៉ាត់កមួយ ក៏លក់មិនសូវដាច់ដែរ"។

សព្វថ្ងៃនេះ បូរ៉ា មានសម្លៀកបំពាក់ ជាអាវធំបែបនេះចំនួនរហូតដល់ទៅ ៧កំប្លេ សម្រាប់ពាក់ផ្លាស់ប្ដូរនៅក្នុងការរកស៊ីប្រចាំថ្ងៃ ដោយចេញលក់ពីពេលព្រឹករហូតដល់ពេលរសៀល។ បូរ៉ាក៏បានឱ្យដឹងថា យុវជនផ្សេងៗទៀតអាចនឹងចាប់ផ្ដើមគំនិតកែច្នៃបែបនេះ ដោយសារតែឥឡូវនេះ មនុស្សគេចូលចិត្តអ្វីដែលប្លែកៗ។

# ដើមអាកាស្យាមិនធ្វើឱ្យដីហិរ និងមានគុណប្រយោជន៍

**ជាត សំភី**



Photo : P. Samphy

បើតាមប្រសាសន៍របស់អ្នកជំនាញ បានឱ្យដឹងថា ដើមឈើអាកាស្យាមិនធ្វើឱ្យដីហិរទេ។ មនុស្សមួយចំនួនយល់ច្រឡំ អាកាស្យា ទៅនឹងដើមប្រេងខ្យល់មានស្លឹកពេលជ្រុះដល់ដី ហើយត្រូវកម្តៅនិងទឹកភ្លៀង វាចេញសារធាតុប្រេងម្យ៉ាងធ្វើឱ្យដី ហិរ និងរុក្ខជាតិផ្សេងទៀតពិបាកលូតលាស់ ។

លោកឃូ អៀងហួត ជាអនុប្រធាននាយកដ្ឋានបេតិកភណ្ឌវប្បធម៌ និងធម្មជាតិនៅគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោកនៃទីស្តីការគណៈរដ្ឋមន្ត្រី បានមានប្រសាសន៍ឱ្យដឹងថា អាកាស្យាជាប្រភេទដើមឈើមិនធ្វើឱ្យដីហិរទេ។ ផ្ទុយទៅវិញ វាជាប្រភេទដើមឈើបៃតង មានន័យថា មិនជ្រុះស្លឹកនៅរដូវប្រាំងដែលផ្តល់ជាគម្របបៃតងរហូត។ លោកបន្តថា លើសពីនេះ គេដាំវាដើម្បីម្លប់ ឬនៅកន្លែងណាដែលមានដីរិចរិល ដើម្បីបំពេញជីវជាតិដល់ដី ព្រោះឫសរបស់វាមានដុំពកដែលអាចស្រូបយកជាតិអាសូតពីបរិយាកាស។

លោកឃូ អៀងហួតបញ្ជាក់ដែរថា ក្រៅពីគុណប្រយោជន៍ជួយផ្តល់ជាគម្របដី និងការពារការហូរច្រោះដី សម្រាប់ស្លឹកវាគេអាចកាត់ឱ្យគោពពែស៊ី។ ចំណែកដើមអាកាស្យាយកទៅធ្វើជាម្សៅអាកាស្យាដើម្បីផលិតក្រដាស គឺលេខមួយតែម្តង។

លោកឃូ អៀងហួត បានមានប្រសាសន៍ឱ្យដឹងទៀតថា ដើមឈើអាកាស្យានេះ យើងអាចដាំបាននៅគ្រប់ទីកន្លែង នៅប្រទេសកម្ពុជាយើង ពោលគឺកន្លែងទឹកតិចក៏ដាំបាន និងកន្លែងមានសំណើមខ្ពស់ក៏ដាំបាន លើកលែងតែតំបន់ព្រៃលិចទឹក ពីព្រោះដើមឈើនេះមិនធន់ទៅនឹងតំបន់មានទឹកជន់ច្រើននោះទេ។អាកាស្យាមិនរើសដីទេ។លោកបន្តទៀតថា បើចង់ដាំអាកាស្យា យើងគួរតែដាំនៅដើមរដូវវស្សា នៅអំឡុងខែឧសភា ពីព្រោះធ្វើដូច្នេះ យើងអាចកាត់បន្ថយការចំណាយក្នុងការថែទាំ។ ប្រសិនយើងដាំនៅខែប្រាំងនោះ យើងត្រូវការស្រោចទឹកច្រើន។ អាកាស្យាគឺជាដើមឈើមិនពិបាកដាំទេ។ បើដាំទៅគឺលូតលាស់ល្អតែម្តង ហើយយើងក៏គ្រាន់តែប្រយ័ត្នការពារកុំឱ្យសត្វស៊ី និងដាំពូកវា ឱ្យត្រូវរដូវកាលទៅ។

លោកឃូ អៀងហួត ក៏គូសបញ្ជាក់ថា បើជំរុញឱ្យប្រជាពលរដ្ឋដាំអាកាស្យា យើងត្រូវគិតដល់ទៅពីរចំនុចសំខាន់។ ទីមួយ បើគិតទៅលើបរិស្ថាន គឺល្អពីព្រោះដំណាំអាកាស្យាជួយដល់បរិស្ថានច្រើន។ ទីពីរ បើគិតទៅដល់កត្តាសេដ្ឋកិច្ច យើងត្រូវគិតថា តើដាំឈើនេះហើយ តើអាចទទួលផលអ្វីមកវិញ? ដូចជា តើមានទីផ្សារលក់ឈើនេះយកធ្វើក្រដាសហើយឬនៅ? ទើបយើងគួរចាប់ផ្តើមដាំ។

**បរិស្ថាន**

## សហគមន៍កម្ពុជាព្រួយបារម្ភអំពីគម្រោងកសាងទំនប់វារីនៅក្នុងប្រទេសឡាវ

សហគមន៍ជនជាតិភាគតិច ដែលមានទីលំនៅតាមដងទន្លេមេគង្គ និងដៃទន្លេនៅភូមិភាគឦសាននៃប្រទេសកម្ពុជា បានព្រួយបារម្ភអំពីផែនការកសាងទំនប់វារីអគ្គិសនីសាយ៉ាបុរីនៅក្នុងប្រទេសឡាវ។

លោកអ៊ុំឯក ស៊ីវិន ប្រជាពលរដ្ឋនៅភូមិស្វាកោះ ឃុំកោះក្រឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង បានអះអាងថា ទោះបីជាតែទំនប់នេះ វានៅក្នុងប្រទេសឡាវ។ ប៉ុន្តែវាអាចប៉ះពាល់ដល់ការនេសាទ និងដាំដំណាំជាពិសេស គឺលិចភូមិករយើងតែម្តង។

ទំនប់សាយ៉ាបុរី គឺជាទំនប់វារីអគ្គិសនីមួយដែលគ្រោងឡើងដោយរដ្ឋាភិបាលឡាវ និងវិនិយោគសាងសង់ ដោយក្រុមហ៊ុនថៃមួយដែលមានទុនវិនិយោគរហូតដល់ទៅ៣,៥ពាន់លានដុល្លារ ជាមួយនិងក្តីរំពឹងថា នឹងផលិតថាមពលអគ្គិសនីបានចំនួន ១,២៦០ មេហ្គាវ៉ាត។ ទំនប់នេះមានទីតាំងនៅក្នុងប្រទេសឡាវ ដែលមានចមាយប្រមាណ ១០០០ គីឡូម៉ែត្រ ពីព្រំដែននៃប្រទេសកម្ពុជានៅក្នុងខេត្តស្ទឹងត្រែង។

លោកឈិត សំអាត នាយកប្រតិបត្តិនៃវេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីអំពីកម្ពុជា បានមានប្រសាសន៍ឱ្យដឹងថា ទំនប់នេះនៅឆ្ងាយមែន។ ប៉ុន្តែផលប៉ះពាល់វាអាចកើតមានមកដល់សហគមន៍នៅតាមដងទន្លេមេគង្គ។ លោកបានបញ្ជាក់ថា : "តាមការសិក្សា និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានទំនប់ គេរកឃើញថា មានត្រីមួយចំនួនបំលាស់ទីពីបឹងទន្លេសាបទៅទន្លេមេគង្គផ្នែកខាងលើ"។

**ខាន់ ភីរម្យ**



Photo : DR

# ក្រុមបព្វជិតាព្រះសហគមន៍កាតូលិក
# ជួយប្រជាជនឱ្យមានការទទួលខុសត្រូវចំពោះសុខភាពពួកគាត់

**ជាត សំភី**

ជារៀងរាល់ខែអ្នកជំងឺប្រមាណ ៥០នាក់ នៅសាលាមត្តេយ្យ និងបឋមសិស្សានានានៅក្រុងព្រះសីហនុបានទទួលនូវការត្រួតពិនិត្យសុខភាពមាត់-ធ្មេញពីក្រុមបងស្រីដូមីនីកតាមរយៈកម្មវិធីការថែរក្សាសុខភាពមាត់ធ្មេញ និងធ្វើការអប់រំសុខភាពបឋម របស់បងស្រី ហើយក្រុមបងស្រីក៏មានគ្លីនីកធ្មេញមួយនៅក្នុងព្រះសហគមន៍កាតូលិក ក្រុងព្រះសីហនុផងដែរ។

តាមប្រសាសន៍របស់បងស្រីអាមេលីយ៉ា អេសវ៉ាមូស សមាជិកក្រុមគ្រួសារបងស្រីសន្តដូមីនិកនៃក្រុងព្រះសីហនុ គឺបានឱ្យដឹងថា បងស្រីដំណើរការកម្មវិធីនេះ តាំងពីពាក់កណ្តាលឆ្នាំ២០០៨ ដោយ-សារតែមានការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាលអ៊ីតាលីមួយ និងសាលាដុនបូស្កូដែលជួយបំពាក់នូវសម្ភារៈផ្សេងៗដូចជាគ្រែព្យាបាលជាដើម។

កម្មវិធីផ្តោតសំខាន់លើការថែរក្សានិងព្យាបាលសុខភាពមាត់ធ្មេញ ដោយសារបងស្រីអាមេលីយ៉ា អេសវ៉ាមូស គឺជាទន្តពេទ្យមកពីប្រទេសភីលីពីន។ ក្រៅពីនេះក៏មានការអប់រំ សុខភាពអនាម័យ និងការសង្គ្រោះបឋម។ បងស្រីអាមេលីយ៉ា អេសវ៉ា-មូស ដែលជានាយកគ្លីនីក មានប្រសាសន៍ឱ្យដឹងថា យើងធ្វើដំណើរពីសាលាមួយទៅសាលាមួយ ដែលមានសាលាមត្តេយ្យ និងសាលាបឋមសិក្សានៅក្នុងក្រុងព្រះសីហនុ។ នៅពេលជួបកូនសិស្សមានបញ្ហាមាត់ធ្មេញ អង្គការអ៊ីតាលីនឹងបញ្ជូនពួកគេមកទីនេះដើម្បីទទួលការព្យាបាល។

កម្មវិធីនេះគ្របដណ្តប់នៅតាមព្រះសហគមន៍នានា នៅតំបន់កំពង់សោម ដូចជាព្រះសហគមន៍បឹងតាព្រហ្ម កោះខ្យង ស្រែអំបិល និងកោះកុង...។ ក្រុមបងស្រីចុះទៅដល់សហគមន៍ផ្ទាល់ដើម្បីធ្វើសកម្មភាពពិនិត្យព្យាបាល និងអប់រំសុខភាព។

បងស្រីមានប្រសាសន៍ឱ្យដឹងថា អ្នកក្រីក្រគឺជាអាទិភាពរបស់យើងក្នុងការជួយផ្តល់សេវាកម្ម ដោយសារតែពួកគាត់មិនមានលទ្ធភាពក្នុងការបង់សេវាសុខភាព។ បងស្រីអាមេលីយ៉ា ក៏បន្តថា: "យើងជួយពួកគាត់ដោយពុំប្រកាន់សាសនាទេ"។ បងស្រី បន្តថា កម្មវិធីផ្តល់សេវាកម្មដល់ ប្រជាជនដោយមិនយកកម្រៃទេ គឺទាំងការពិនិត្យព្យាបាល និងថ្នាំសង្កូវ។ ប៉ុន្តែប្រជាជនអាចបង់ថ្លៃតាមលទ្ធ-



ភាពរបស់ពួកគាត់។ បងស្រីក៏បន្ថែមដោយញញឹមថា កន្លងមកប្រជាជនខ្លះមិនបានបង់លុយ។ តែពួកគាត់បានផ្តល់ជាផ្លែឈើដូចជាស្វាយ ខ្នុរ... និងចំណីអាហារផ្សេងៗដើម្បីជាកិច្ចថ្លែងអំណរគុណយើង។

បងស្រីអាមេលីយ៉ា គូសបញ្ជាក់ដែរថា: "កម្ម-វិធីពិនិត្យព្យាបាល និងថែរក្សាសុខភាពមាត់ធ្មេញ សុខភាពបឋម ឬការសង្គ្រោះបឋម និងការអប់រំសុខភាពអនាម័យ យើងធ្វើឡើងក្នុងគោលបំណងជួយសម្រាលការលំបាករបស់ប្រជាជនកម្ពុជា ឱ្យពួកគាត់បានយល់ដឹងអំពីសុខភាព និងដឹងអំពីទង្វើត្រឹមត្រូវដែលពួកគាត់ត្រូវការធ្វើសម្រាប់សុខភាពតាមរយៈការអប់រំ ដូចជាការបរិភោគចំណីអាហារត្រឹមត្រូវ និងបរិភោគទឹកឆ្អិន។ ដូច្នេះពួកគាត់អាចមានការទទួលខុសត្រូវចំពោះសុខភាពខ្លួនឯង។

លោកនួ ចន្ទសារឿន អាយុ ៦០ឆ្នាំ ទទួលបន្ទុកគណៈកម្មការសង្គហៈនៃព្រះសហគមន៍ក្រុងព្រះ-សីហនុ មានប្រសាសន៍ឱ្យដឹងថា លោកមានការឈឺចាប់យ៉ាងខ្លាំងជាមួយនិងជំងឺធ្មេញពីមុន។ បន្ទាប់ពីបងស្រីធ្វើការដកធ្មេញឈឺនោះចោល លោកក៏មានអារម្មណ៍សប្បាយចិត្តពីព្រោះលោកលែងឈឺចាប់ទៀតហើយ។ លោកបញ្ជាក់ទៀតដែរថា: "បងស្រីបានជួយយើងឱ្យសប្បាយចិត្តមែនទែន ពីព្រោះបើយើងចំណាយប្រាក់ព្យាបាលធ្មេញនៅខាងក្រៅនឹងធ្វើឱ្យការចំណាយក្នុងគ្រួសារខ្វះខាត។ ប៉ុន្តែយើងត្រូវដឹងថា ទាំងសម្ភារៈ ទាំងថ្នាំ និងសេវាកម្មទាំងអស់នេះសុទ្ធតែត្រូវការប្រាក់។ ដូច្នេះយើងត្រូវតែជួយបង់តាមលទ្ធភាពរបស់យើងផងដែរ"។

ចំណែកកញ្ញាស៊ិន ចន្ថា អាយុ ២៥ឆ្នាំ រស់នៅឯភូមិថ្មីសង្កាត់៣ ក្រុងព្រះសីហនុ បាននិយាយដែរថា កញ្ញាមានជំងឺដង្កូវស៊ី ហើយបានមកព្យាបាលចំនួនបីដងហើយឥឡូវនេះ ក៏មានការធូរស្បើយច្រើន។ កញ្ញាបញ្ជាក់ថា: "ខ្ញុំយល់ថាកម្មវិធីរបស់បងស្រីគឺល្អណាស់ដោយព្យាបាលដល់អ្នកឈឺធ្មេញ ពិសេសអ្នកក្រីក្រ។ គាត់ធ្វើដូច្នេះគឺល្អមែនទែន"។

នូ សក្កនា អាយុ ១៣ឆ្នាំ ជាអ្នកជំងឺម្នាក់ទៀតនិយាយដែរថា ការព្យាបាលរបស់បងស្រីបានធ្វើឱ្យការរស់នៅគេមានសភាពស្រួលជាងមុន។ គេអាចរៀនអានអក្សរដោយមិនមានការដឈឺធ្មេញ។ ពីមុន ធ្មេញគេដង្កូវស៊ី គេវេទនា ឈឺចាប់ និងពិបាកទ្រាំហើយហូបអ្វីក៏មិនបាន។ ប៉ុន្តែឥឡូវនេះគេបានព្យាបាលជាដោយមិនអស់លុយ ធ្វើឱ្យគេសប្បាយចិត្តនិងមានអារម្មណ៍ល្អជាខ្លាំង។

Photos : P. Samphy



បងស្រីអាមេលីយ៉ា អេសវ៉ាមូស កំពុងធ្វើការព្យាបាលយ៉ាងយកចិត្តទុកដាក់ដល់អ្នកដែលមានបញ្ហាធ្មេញនៅគ្លីនិកបងស្រី



Photo : S. Philong

**ខាន់ ភិរម្យ**

## បីខែដើមឆ្នាំកម្ពុជាទទួលបានគម្រោងវិនិយោគតម្លៃ ២៨០ លានដុល្លារ

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអះអាងថា ក្នុងរយៈពេលបីខែដើមឆ្នាំ ២០១១នេះ កម្ពុជាទទួលគម្រោងវិនិយោគ ២៨០លានដុល្លារ ។

ផ្អែកទៅតាមប្រភពដដែលនោះ ក្នុងរយៈពេលត្រីមាសទីមួយដើមឆ្នាំ ២០១១ គម្រោងវិនិយោគនៅប្រទេសកម្ពុជាធ្លាក់ចុះប្រមាណ ៦៦% បើប្រៀប ធៀបជាមួយនឹងតួលេខក្នុងអំឡុងរយៈពេលដូចគ្នា ឆ្នាំ២០១០ ។

គម្រោងវិនិយោគនៅក្នុងដើមឆ្នាំ ២០១១នេះ គឺថយចុះប្រមាណជា ៥៦៥លានដុល្លារ ខណៈដែលកាលពីឆ្នាំ២០១០ គឺមានរហូតដល់ទៅ ៨៤៦ លានដុល្លារ ។

ក្នុងរយៈពេលមួយត្រីមាស ដើមឆ្នាំនេះអាមេរិក គឺជាប្រទេសនាំមុខគេនៅក្នុងទីផ្សារវិនិយោគនៅប្រទេសកម្ពុជា ក្នុងតម្លៃប្រមាណជា ៩៥លានដុល្លារ បន្ទាប់មកមានមកពី កោះតៃវ៉ាន់ កូរ៉េខាងជើង ចិន ម៉ាឡេស៊ី និងប្រទេសកូរ៉េខាងត្បូងជាដើម ។

## វៀតណាមប្រកាសបើកទីផ្សារមូលបត្ររបស់ខ្លួននៅកម្ពុជា

ក្រុមហ៊ុនមូលបត្រកម្ពុជា-វៀតណាមភីអ៊ិលស៊ីបានប្រកាសបើកប្រតិបត្តិការរបស់ខ្លួនក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាពរបស់លោក ឃ្វៀន តិនយ៉ុង នាយករដ្ឋមន្ត្រីវៀតណាម និងសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា កាលពីថ្ងៃទី២៤ ខែមេសាកន្លងទៅនេះ ។

នេះគឺជាក្រុមហ៊ុនមូលបត្រទីមួយដំណើរការក្នុងប្រទេសកម្ពុជា ដែលមានមូលធនតម្កល់ ១០លានដុល្លារ និងជាក្រុមហ៊ុនតែមួយគត់ ដែលបានអនុញ្ញាតឱ្យអនុវត្តពេញលេញលើការងារជំនាញមូលបត្រនៅកម្ពុជា ។

សេវាកម្មដែលក្រុមហ៊ុននេះនឹងបម្រើអតិថិជន រួមមានការផ្តល់ប្រឹក្សាយោបល់ផ្នែកវិនិយោគ អន្តរការីផ្នែកមូលបត្រ ការផ្តល់ប្រឹក្សាយោបល់ផ្នែកហិរញ្ញកិច្ច សហគ្រាស អាជីវកម្មការធានាចេញផ្សាយ និងធនាគារវិនិយោគ ។

## ទំនាស់ព្រំដែនកម្ពុជា-ថៃ ឈានដល់ការវាយប្រហារដោយអាវុធម្តងទៀត

ទំនាស់ព្រំដែនកម្ពុជា-ថៃបានឈានដល់ការវាយប្រហារគ្នាដោយអាវុធជាថ្មីម្តងទៀតកាលពីចុងខែមេសាកន្លងទៅនេះ ។

យោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការពារជាតិបានឱ្យដឹងថា ការវាយប្រហារបានចាប់ផ្តើមតាំងតែពីម៉ោង ៦ : ១៥នាទីព្រឹក ថ្ងៃទី២២ ខែមេសា ដោយទាហានថៃវាយប្រហារឈ្លានពានមកលើទឹកដីកម្ពុជា នៅប្រាសាទតាមាន់ និងតំបន់ប្រាសាទតាក្របី ខេត្តឧត្តរមានជ័យ ។

ការប្រយុទ្ធនៅថ្ងៃដំបូងបណ្តាលឱ្យភាគីកម្ពុជា ពលីជីវិតទាហានចំនួន ៧ រូប និងរបួសចំនួន ១៧រូប ។

ការវាយប្រហារបន្តអូសបន្លាយរហូតដល់ថ្ងៃទី៣ ខែឧសភា ហើយសភាពការនៅតែបន្តតានតឹង ។ ការប្រយុទ្ធនេះបានបណ្តាលឱ្យប្រជាជនកម្ពុជារាប់ពាន់នាក់ភៀសខ្លួនពីភូមិដោយសារតែភាគីថៃបាញ់ផ្លោងចូលជ្រៅទៅក្នុងភូមិសាស្ត្រប្រទេសកម្ពុជា ជាពិសេស គឺភូមិដ្ឋានអ្នកស្រុក ។

## អូសាម៉ា ប៊ិនឡាដេន ស្លាប់ក្រោយការវាយឆ្មក់របស់អាមេរិក

អូសាម៉ា ប៊ិនឡាដេន ដែលគេស្គាល់ទូទាំងពិភពលោកថា ជាមេដឹកនាំភេរវករអាល់កៃដា បានបាត់បង់ជីវិតក្រោយពីការវាយឆ្មក់របស់អាមេរិកកាលពីថ្ងៃទី២ ខែឧសភា។

លោកបារ៉ាក់ អូបាម៉ា ប្រធានាធិបតីអាមេរិកអះអាងថា អូសា-ម៉ា ប៊ិនឡាដេនបានស្លាប់នៅក្នុងតំបន់អាបូដាបាតនៃប្រទេសប៉ាគីស្ថាន។

អូសាម៉ា ប៊ិនឡាដេនគឺជាមេដឹកនាំភេរវករមួយនៅក្នុងចំណោមភេរវករចំនួន១០នាក់ ដែលពិភពលោកកំពុងតែត្រូវការប្រមាញ់។ លោកកើតនៅក្នុងថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៥៧ ក្នុងត្រកូលមហាសេដ្ឋីមួយនៅក្នុងប្រទេសអារ៉ាប៊ី សាអូឌីត។

លោកអូសាម៉ា ប៊ិនឡាដេន គឺជាអ្នកដឹកនាំការវាយប្រហារអគារពាណិជ្ជកម្មពិភពលោកនៅញូវយ៉ក កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១។ ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១១ អូសាម៉ា ប៊ិនឡាដេន ត្រូវបានគេអះអាងថា ជាមេដឹកនាំ ភេរវករដែលបានដឹកនាំការវាយប្រហារផ្សេងៗ ដែលបណ្តាលឱ្យបាត់បង់ជីវិតជនស៊ីវិលប្រមាណ ៨០០០០ ទៅ ១,២លាននាក់ នៅក្នុងប្រទេសអ៊ីរ៉ាក់ អាហ្គានីស្ថាន និងប្រទេសសូម៉ាលីជាដើម ។

## ជប៉ុនប្រកាសរុករកសាកសពដោយសារតែស៊ូណាមិ ក្នុងទ្រង់ទ្រាយធំ

ជប៉ុនបានអះអាងថា ប្រទេសខ្លួនបានប្រើប្រាស់ទូវកងទ័ពរហូតដល់ទៅ ២៥០០០នាក់ ដើម្បីបំពេញបេសកកម្មរុករកសាកសពដោយសារតែរលករញ្ជួយដី និងស៊ូណាមិជាលើកទី២ ។

យោងទៅតាមបណ្តាញព័ត៌មាន ឆាណែលញូវអេស៊ី បានឱ្យដឹងថា ដោយសារតែគ្រោះធម្មជាតិមួយនេះ នៅមានជនរងគ្រោះប្រមាណជា ១២០០០នាក់ទៀតដែលបានបាត់ខ្លួន ។ ប្រតិបត្តិការរុករកនេះបានចាប់ផ្តើម កាលពីថ្ងៃទី២៥ ខែមេសា ដើម្បីធ្វើការរុករកសាកសពដែលស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ ។

យោងតាមប្រភពដដែលនោះ បានឱ្យដឹងថា បេសកកម្មនេះក៏មានការចូលរួមពីកងទ័ពអាមេរិក ដែលមានមូលដ្ឋាននៅជប៉ុនខ្លះផងដែរ ។

ជប៉ុនបានទទួលរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដោយសាររលកស៊ូណាមិ និងការរញ្ជួយដីកាលពីថ្ងៃទី១១ ខែមីនា ដោយបានសម្លាប់ជីវិតមនុស្សប្រមាណ ១៤០០០នាក់ និងបំផ្លាញសេដ្ឋកិច្ចជប៉ុនអស់រាប់ពាន់លានដុល្លារ ពិសេសមានមហន្តរាយនៃការធ្លាយវិទ្យុសកម្មពីរោងចក្រអគ្គិសនីដើរដោយថាមពលនុយក្លេអ៊ែរនៅតំបន់រងគ្រោះ ។



Photo : DR

# តើការអភិរក្សមានអត្ថន័យ និងបញ្ហាប្រឈមយ៉ាងណា?

**ខាន់ ភីរម្យ**

*សព្វថ្ងៃនេះនៅទីណាក៏ឮសូរតែពាក្យថា អភិរក្សដែរសូម្បីតែនៅតាមទីជនបទ។ ប៉ុន្តែតើមិត្តអ្នកអានយល់អ្វីខ្លះពីពាក្យនេះ? ហើយថា តើការអភិរក្សនេះ គេដំណើរការដោយរបៀបណា? គេអនុវត្តយ៉ាងម៉េច។ អ្នកនាំសារសូមណែនាំមិត្តអ្នកអានឱ្យជួបជាមួយនិងលោកមាច មៀន អ្នកសម្របសម្រួលនៃអង្គការបណ្តាញការពារទន្លេសេសាន សេកុង និងស្រែពក ក្នុងខេត្តរតនគិរី។*



លោកមៀច មាន និងតំណាងអង្គការដៃគូកំពុងសិក្សាស្វែងយល់ក្នុងព្រៃអភិរក្ស

**អ្នកនាំសារ: បើតាមយោបល់របស់លោក តើការអភិរក្សមានអត្ថន័យយ៉ាងណា?**

**លោកមាច មៀន:** អ្នកខ្លះមានយោបល់ថា ការអភិរក្សគឺជាការប្រឆាំងនឹងការអភិវឌ្ឍន៍។ ប៉ុន្តែវាមិនមែនមានន័យដូច្នេះឡើយ។ អភិរក្ស មានន័យថា ជាការការពារនូវធនធានធម្មជាតិ និងជំរុញឱ្យការប្រើប្រាស់នូវធនធានធម្មជាតិ អាចដំណើរការទៅប្រកបដោយនិរន្តរភាព។

**អ្នកនាំសារ : តើនរណាខ្លះអាចចូលរួមធ្វើការងារអភិរក្សនេះ?**

**លោកមាច មៀន:** ការអភិរក្សគឺជាការងាររបស់មនុស្សគ្រប់ៗគ្នានៅលើពិភពលោកនេះ។ នរណាក៏អាចចូលរួមការងារអភិរក្សនេះបានដែរ។ ហើយដើម្បីចូលរួម គេទាមទារឱ្យមានការបរិច្ចាគ និងធ្វើការងារស្ម័គ្រចិត្ត និងត្រូវការចំណាយនូវពេលវេលាច្រើន ជាពិសេសគឺការងារដែលនៅជាប់ជាមួយនិងសហគមន៍។ អ្នកដែលធ្វើការងារអភិរក្សបានជោគជ័យ គឺលុះត្រាតែអ្នកនោះស្រលាញ់ និងចូលចិត្តរស់នៅក្នុងធម្មជាតិ។

**អ្នកនាំសារ : តើអ្វីខ្លះដែលជាបញ្ហាប្រឈមរបស់អ្នកអភិរក្សទាំងឡាយ?**

**លោកមាច មៀន:** ការអភិរក្សមិនមែនជាការងារដែលងាយស្រួលទេ។ ជួនកាលការងារអភិរក្សនេះអាចត្រូវរងនូវការចោទប្រកាន់ថា ប្រឆាំងនឹងការអភិវឌ្ឍន៍។បញ្ហាប្រឈមមុខមួយទៀតគឺកង្វះខាតការចូលរួម កិច្ចសហការ ក៏ដូចជាបញ្ហាមូលនិធិ។



Photos : 3SPN

លោកមាច មៀន អ្នកសម្របសម្រួលនៃអង្គការបណ្តាញការពារទន្លេ សេសាន សេកុង និងស្រែពក នៅក្នុងខេត្តរតនគិរី កំពុងធ្វើការដឹកនាំតំណាងអង្គការដៃគូដើម្បីមើលសិក្សាស្វែងយល់នៅតំបន់ធម្មជាតិដែលនឹងត្រូវចូលរួមធ្វើការអភិរក្ស។

**អ្នកនាំសារ : តើហេតុអ្វីបានជាការអភិរក្សប្រឈមមុខនឹងការលំបាកទាំងបីធំខាងលើនេះ?**

**លោកមាច មៀន:** ជោគជ័យការងារអភិរក្សអាចទទួលបានលុះត្រាតែមានការចូលរួម។ ប៉ុន្តែដោយសារតែកត្តាជីវភាព ប្រជាជនភាគច្រើនត្រូវការធ្វើការងារផ្សេងៗដើម្បីបានប្រាក់ចំណូលយកចិញ្ចឹមគ្រួសារ។ ដូច្នេះពួកគេពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមសកម្មភាពយើងឡើយ។ បញ្ហាមួយទៀត ជួនកាលសហគមន៍មានការចូលរួមច្រើននៅក្នុងសកម្មភាពអភិរក្សអ្វីមួយ។ តែការចូលរួមនោះត្រូវការផ្តោះរបងមួយទៀត គឺការស្វែងរកនូវកិច្ចសហការពីអាជ្ញាធរ។

**អ្នកនាំសារ : ក្នុងនាមលោកជាអ្នកអភិរក្សមួយរូប តើលោកជួបប្រទះនឹងបញ្ហាប្រឈមអ្វីខ្លះ?**

**លោកមាច មៀន:** សម្រាប់ខ្លួនខ្ញុំផ្ទាល់ ដែលបានប្រឡូកក្នុងការងារអភិរក្សនេះ បញ្ហាប្រឈមដែលបានជួបប្រទះ គឺសមត្ថភាព ពេលវេលា និងធនធានមនុស្ស។ ថ្វីត្បិតតែការងារអភិរក្ស គឺនរណាក៏អាចចូលរួមបាន។ ប៉ុន្តែនេះនឹងពុំបានជោគជ័យ បើគ្មានសមត្ថភាព និងធនធានមនុស្សដឹកនាំនោះទេ។ តួយ៉ាង អង្គការយើងធ្វើការជាមួយសហគមន៍ជនជាតិភាគតិច ហើយធនធានមនុស្សនៅសហគមន៍មានការខ្វះខាតច្រើន ដែលទាមទារឱ្យមានការបណ្តុះបណ្តាលច្រើនដើម្បីឱ្យការងារអភិរក្ស អាចដំណើរការទៅប្រកបដោយប្រសិទ្ធភាព។

### តើអង្គការបណ្តាញការពារទន្លេសេសាន សេកុង និងស្រែពកធ្វើការអភិរក្សអ្វី?

អង្គការបណ្តាញការពារទន្លេសេសានសេកុង និងស្រែពក គឺជាអង្គការក្រៅរដ្ឋាភិបាលមួយនៅភូមិភាគឦសាននៃ ប្រទេសកម្ពុជាហើយធ្វើការអភិរក្សផ្តោតលើទន្លេទាំងបីខាងលើ។

លោកមាច មៀន ប្រាប់ថា: "យើងកំពុងសហការ និងធ្វើសកម្មភាពដោយផ្ទាល់ជាមួយអង្គការដៃគូលើការអភិរក្សទន្លេបី គឺសេសាន សេកុង និងស្រែពក នៅ ១២៦សហគមន៍ នៅក្នុងខេត្តបី គឺខេត្តរតនគិរី មណ្ឌលគិរី និងស្ទឹងត្រែង។ គោលបំណងយើង គឺជំរុញឱ្យការប្រើប្រាស់ទឹក និងធនធានធម្មជាតិក្នុងទន្លេទាំងបីនេះ ឱ្យមាននិរន្តរភាព"។

# ភាពក្រីក្រ និងប្រពៃណី គឺជាកត្តាសំខាន់ជំរុញ ន

**ខាន់ ភីរម្យ**

ទោះបីជាអ្នកជំនាញមានសុទិដ្ឋិនិយមថា កម្ពុជាអាចនឹងឈានឆ្ពោះទៅរកការលុបបំបាត់ ពលកម្មកុមារបាន ក្នុងឆ្នាំ២០១៦ ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះភាពក្រីក្រ និងកត្តាប្រពៃណី គឺជាកត្តាចលករដ៏សំខាន់ ដែលជំរុញឱ្យមានពលកម្មកុមារ នៅក្នុងប្រទេសកម្ពុជា ។

លោកជួន រិទ្ធី ជាប្រធានអង្គការសង្គ្រោះក្មេងងាយរងគ្រោះ ដែលមានទីស្នាក់ការនៅខេត្តបាត់ដំបងឱ្យដឹងថា ភាពក្រីក្រ និងប្រពៃណីនេះជាឧបសគ្គមួយធំណាស់ ក្នុងការជំរុញ និងអនុវត្តនូវផែនការរបស់រាជរដ្ឋាភិបាលក្នុងការលុបបំបាត់ពលកម្មកុមារ និងផែនការអប់រំដើម្បីទាំងអស់គ្នា ។ លោកបានបញ្ជាក់ថា : "ដោយសារតែភាពក្រីក្រ មនុស្សសឹងតែមួយឃុំធ្វើចំណាកស្រុកចេញទៅរកការងារធ្វើនៅទីក្រុង និងនៅប្រទេសថៃ ។ មនុស្សអត់ដេកចាំស្លាប់ទេ ។ ទោះបីជាដឹងថា បើទៅ វាប្រថុយនឹងគ្រោះថ្នាក់ នៅតែទៅ" ។

បើតាមប្រសាសន៍របស់លោកជួន រិទ្ធី ឃុំមួយដែលមានមនុស្សភាគច្រើនធ្វើចំណាកស្រុកទៅរកការងារធ្វើនោះ គឺឃុំសំរោងស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ក្មេងៗអាចទៅតាមឪពុកម្តាយ និងជួយការងារឪពុកម្តាយរបស់គេ ។ ខ្លះក៏ទៅសុំទាន ។ រីឯយុវជន និងមនុស្សពេញវ័យ ទៅធ្វើការតាមចំការ -ល- ។ លោកបានបន្តទៀតថា នេះគឺជាស្ថានភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ នៅឯក្នុងឃុំសំរោង ។ តែសម្រាប់ស្ថានភាពកុមារនៅតាមតំបន់ជុំវិញបឹងទន្លេសាបវិញនោះក្រៅពីភាពក្រីក្រ ហើយវាអាចមានប្រពៃណីនេះទៀត ។ លោកគិតថាវាគឺជាឧបសគ្គដែលនាំឱ្យមានការលំបាក ក្នុងការលុបបំបាត់ពលកម្មកុមារនិងផែនការអប់រំដើម្បីទាំងអស់គ្នា ។ លោកបានឱ្យដឹងថា កុមារភាគច្រើនដែលនៅតំបន់ជុំវិញបឹងទន្លេសាបគឺអត់សូវរវល់ទៅនឹងការសិក្សាទេ ។ពួកគេភាគច្រើនអត់ចេះអក្សរ ។ លោកបញ្ជាក់ថា: "កុមារភាគច្រើនដែលខ្ញុំជួប មានអាយុ ១៦ឆ្នាំ ហើយអត់ដែលស្គាល់ថា សាលានិងការសិក្សានោះមានរូបរាងយ៉ាងម៉េចនោះទេ ។ពួកគេស្គាល់តែមងស្គាល់អួន ទូក ទឹក និងព្រៃតែប៉ុណ្ណោះ" ។ លោកក៏បានឱ្យដឹងទៀតថា មូលហេតុដែលពួកគេមិនស្គាល់សាលានេះ គឺមិនមែនដោយសារនៅតំបន់បឹងទន្លេសាបទាំងមូល គ្មានសាលារៀននោះទេ ។ ប៉ុន្តែជីវភាព និងប្រពៃណីនៃការរស់នៅ គឺតម្រូវពួកគេឱ្យទៅជួយពលកម្មគ្រួសារ ដែលធ្វើឱ្យឃ្លាតឆ្ងាយ ពីការអប់រំ ។ លោកបានបន្តទៀតថា មួយឆ្នាំៗ មានកុមារជាច្រើន មិនស្គាល់ថា ដីគោកយ៉ាងម៉េចផង? ពួកគេតែងទៅតាមគ្រួសារនេសាទត្រី ឆ្ងាយចេញពីភូមិ ស្រុកពីសហគមន៍ និងទៅតាមព្រៃលិចទឹក ។

ទាក់ទិននិងបញ្ហាពលកម្មកុមារនេះ កុមារីម្នាក់អាយុ ១៥ឆ្នាំ ឈ្មោះគីម ដែលមិនចាំទីលំនៅរបស់ខ្លួនគ្រាន់តែចាំថា មកពីខេត្តកំពង់ធំ ដែលកំពុងតែមករកការងារធ្វើនៅក្នុងទីក្រុងភ្នំពេញនិយាយថា ដោយសាររឿងជីវភាពនាង និងគ្រួសារ ។ នាងបានចេញពីផ្ទះ និងចោលដីស្រែជាច្រើនដង ដើម្បីទៅប្រទេសថៃធ្វើជាអ្នកដកដំឡូងនិងធ្វើចំការ ។ ប៉ុន្តែនៅលើកនេះ នាងបានមករកការងារធ្វើនៅទីក្រុង



### ឧបសគ្គនៃការលុបបំបាត់ពលកម្មកុមារ គឺភាពក្រីក្រ

លោកអ៊ុន វុទ្ធី មន្ត្រីកម្មវិធីអន្តរជាតិស្តីអំពីការលុបបំបាត់ពលកម្មកុមារនៃអង្គការពលកម្មអន្តរជាតិ មានសុទិដ្ឋិនិយមថា កម្ពុជាអាចលុបបំបាត់ពលកម្មកុមារបានតាមគោលដៅ។ ប៉ុន្តែកម្ពុជាក៏មិនត្រូវបំភ្លេចអំពីការកាត់បន្ថយភាពក្រីក្រនោះទេ។ លោកបានឱ្យដឹងថា ភាពក្រីក្រ និងពលកម្មកុមារ គឺវាមានទំនាក់ទំនងនឹងគ្នា។ លោកបានបញ្ជាក់ឱ្យដឹងទៀតថា : "ភាពក្រីក្រធ្វើឱ្យមានពលកម្មកុមារ។ ហេតុដូច្នេះហើយបើមានភាពក្រីក្រនៅកន្លែងណា ពលកម្មកុមារក៏មិនអាចលុបបំបាត់បានដែរ"។

យោងទៅតាមរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាបានឱ្យដឹងថា អត្រានៃភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០១០ គឺនៅសល់ប្រមាណជា២៧,៣% ហើយនៅក្នុងមួយឆ្នាំ កម្ពុជាអាចកាត់បន្ថយអត្រានេះបាន ១% ផងដែរ។

# ញ នាំឱ្យមានពលកម្មកុមារ



Photo : S. Philong

ភ្នំពេញ ដោយសារតែការចេញចូលប្រទេសថៃត្រូវបានអាជ្ញាធររឹតបន្តឹង។

គីមគឺជាកុមារីម្នាក់ ដែលមិនដែលស្គាល់សាលារៀន។ ហើយមកដល់ពេលនេះ នាងអត់ចេះអក្សរសូម្បីតែអក្សរក ឬ លេខ១ ។

នេះជាស្ថានភាពរបស់កុមារីចំណាកស្រុកមួយរូប។ ប៉ុន្តែបើតាមសំដីរបស់កុមារាលក់ផ្កាម្នាក់បានឱ្យដឹងថារូបគេគឺជាអ្នកដែលរស់នៅភ្នំពេញ។ ប៉ុន្តែគេតែងតែមកជួយលក់ផ្កាម្តាយរបស់គេ ដើម្បីបានប្រាក់កាសខ្លះយកទៅរៀន។

កុមារារូបនោះ បានអះអាងថា បើគេរៀនពេលព្រឹកគេមកជួយលក់ពេលរសៀល ឬក៏ពេលល្ងាច។ តែបើរៀនពេលរសៀលគេនឹងមកជួយម្តាយរបស់គេនៅពេលព្រឹក។

សព្វថ្ងៃនេះកុមារាម្នាក់នេះគឺមានអាយុ ១៤ឆ្នាំ កំពុងសិក្សា នៅថ្នាក់ទី៥ ក្រោមការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាលមួយ។ កុមារាម្នាក់នេះបានអះ-អាងថា: "អង្គការជួយខ្ញុំ អត់ឱ្យខ្ញុំលក់ទេ។ ប៉ុន្តែខ្ញុំអាណិតម៉ែ ក៏មកជួយគាត់ទៅ"។

ជុំវិញបញ្ហានេះលោកអ៊ុន វុទ្ធី ដែលជាមន្ត្រីកម្ម-វិធីអន្តរជាតិស្តីអំពីការលុបបំបាត់ពលកម្មកុមារនៃអង្គការពលកម្មអន្តរជាតិ ក៏បានមានប្រសាសន៍ថាបើតាមច្បាប់ការងាររបស់កុមារា និងកុមារី ដែលរៀបរាប់ខាងលើនេះ ចូលក្នុងពលកម្មកុមារ ដែលច្បាប់ហាមឃាត់ ហើយប្រទេសកម្ពុជាគឺកំពុងប្រឹងប្រែងដើម្បីឈានទៅរកការលុបបំបាត់។

លោកបញ្ជាក់ថា: "ពលកម្មកុមារនៅកម្ពុជានៅមិនទាន់លុបបំបាត់បាននៅឡើយទេ។ ប៉ុន្តែរដ្ឋាភិ-បាល និងផ្នែកដែលពាក់ព័ន្ធមានយន្តការ និងការប្តេជ្ញាចិត្តរួចទៅហើយនៅក្នុងការឈានទៅរកការលុបបំបាត់ពលកម្មកុមារនេះ"។ លោកបានឱ្យដឹងថា តាមការប៉ាន់ប្រមាណ នាពេលបច្ចុប្បន្ននេះ នៅទូទាំងកម្ពុជា មានកុមារ អាយុពី ៥ឆ្នាំ ទៅដល់១៧ឆ្នាំដែលកំពុងតែស្ថិតនៅក្នុងទម្រង់ការងារពលកម្មធ្ងន់ធ្ងរនោះ គឺមានរហូតដល់ទៅប្រមាណជា ៣០០ ០០០នាក់។ លោកបានបន្តទៀតថា ពួកគេគឺកំពុងធ្វើការនៅក្នុងប្រភេទការងារចំនួន ៣៨មុខ ដោយរាប់តាំងពីការងារនេសាទ ចំការ កៅស៊ូ កុមារស៊ីឈ្នួលតាមផ្ទះការងារសំណង់ វាយថ្ម និងនៅឡឥដ្ឋជាដើម-ល-។ លោកបានឱ្យដឹងទៀតថា បើតាមច្បាប់ កុមារអាចនឹងធ្វើការងារ បានលុះត្រាតែគេមានអាយុចាប់ពី១៥ឆ្នាំឡើង។ ប៉ុន្តែការងារដែលច្បាប់អនុញ្ញាតនោះ លុះត្រាតែការងារនោះ គឺជាការងារដែលមិនប៉ះពាល់ទៅដល់សុខភាព និងមិនរំខានដល់ការសិក្សារបស់កុមារ។ ការងារទាំងនោះមានដូចជា ការចិញ្ចឹមសត្វក្នុងគ្រួសារ ជម្រះស្មៅដីតិចតួច និងដាំកូនឈើ-ល-។

បើទោះបីជាក្នុងពេលបច្ចុប្បន្ននេះ អត្រាពល-កម្មកុមារដែលធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជាត្រូវគេប៉ាន់ប្រមាណថា វាមានរហូតដល់ទៅ ៣០០០០០នាក់ក៏ដោយ។ ប៉ុន្តែប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងអាចលុបបំបាត់ពលកម្មកុមារនេះឱ្យបាននៅក្នុងឆ្នាំ២០១៦ ខាងមុខនេះ។

លោកអ៊ុនវុទ្ធីបានបញ្ជាក់ដែរថា: "យើងក៏មានសុទិដ្ឋិនិយមដែរថា កម្ពុជាអាចនឹងឈានទៅរកការលុបបំបាត់ពលកម្មកុមារនេះ ឱ្យបានក្នុងឆ្នាំ២០១៦ តាមគោលដៅដែលបានកំណត់ដោយសារតែយើងពិនិត្យទៅឃើញថា នៅពេលនេះ កម្ពុជាមានទាំងឆន្ទៈ និងមានយន្តការ"។ លោកបានឱ្យដឹងថា កន្លងមក កម្ពុជាក៏បានអះអាងដើម្បីលុបបំបាត់ពលកម្មកុមារពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៦ ដែលត្រូវថវិកាប្រមាណ ៩០លានដុល្លារ។ លោកបានឱ្យដឹងថា នេះគឺជាចំនួនថវិកាមួយដ៏ច្រើន។ ប៉ុន្តែលោកមានជំនឿថា កម្ពុជាអាចស្វែងរកថវិកានេះបាន។ លោកបានបញ្ជាក់ថា: "ក្នុងមួយឆ្នាំយើងទទួលជំនួយប្រមាណជា១០០០លានដុល្លារ។ ដូច្នេះបើរដ្ឋាភិបាលយកត្រឹមតែ១% នៃប្រាក់ជំនួយនេះក្នុងមួយឆ្នាំ កម្ពុជាអាចមានថវិកាប្រមាណ ១០លានដុល្លារ សម្រាប់ធ្វើកិច្ចការលុបបំបាត់ពលកម្មកុមារនេះ ហើយទំរាំដល់ឆ្នាំ២០១៦ កម្ពុជាអាចប្រមូលបានថវិកាយ៉ាងហោចណាស់ ក៏៧០លានដុល្លារដែរចុះបូក នឹងការគៀងគរថវិកាផ្សេងៗទៀត។ ដូច្នេះយើងជឿថា ថវិកាមិនមែនជាឧបសគ្គទេ"។ លោកបន្តទៀតថា ក្រៅពីបញ្ហាថវិកា មកដល់ពេលនេះ កម្ពុជាក៏បានបង្កើតនូវយន្តការជាច្រើនតាំងពីថ្នាក់ក្រសួងរហូតដល់ថ្នាក់ខេត្តដើម្បីដោះស្រាយបាន។

## កម្ពុជារកឃើញមានកុមារ ១,៥លាននាក់ ស្ថិតនៅក្នុងសកម្មភាពសេដ្ឋកិច្ច

បើយោងតាមការសិក្សាមួយដែលឧបត្ថម្ភដោយអង្គការពលកម្មកុមារអន្តរជាតិកាលពីឆ្នាំ២០០១ បានឱ្យដឹងថា នៅទូទាំងប្រទេសកម្ពុជា គេរកឃើញថា កុមារដែលស្ថិតនៅក្នុងសកម្មភាពសេដ្ឋកិច្ចនោះ មានចំនួនរហូតដល់១,៥លាននាក់។

ការសិក្សានោះបានរកឃើញផងដែរថា នៅក្នុងចំណោមកុមារ ១,៥លាននាក់នោះ គេរកឃើញថា ពលកម្មកុមារមានចំនួន ៧៥០០០០ នាក់ ហើយកុមារដែលស្ថិតនៅក្នុងពលកម្មធ្ងន់ធ្ងរនោះ គឺមាន ២៥០០០០នាក់។

លោកអ៊ុន វុទ្ធី មន្ត្រីកម្មវិធីអន្តរជាតិស្តីអំពីការលុបបំបាត់ពលកម្មកុមារនៃអង្គការពលកម្មអន្តរជាតិឱ្យដឹងថា មកដល់ពេលនេះនៅមិនទាន់មានការសិក្សាផ្លូវការដែលគេធ្វើនៅលើពលកម្មកុមារនៅឡើយទេ។ ប៉ុន្តែគេប៉ាន់ប្រមាណថា កុមារដែលកំពុងតែធ្វើការនៅក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរនោះ គឺមានចំនួន ៣០០០០០នាក់។ នេះគឺដោយសារតែកំណើនប្រជាជនផងដែរ។

# ព្រះសហគមន៍កាតូលិកកំពង់ចាម បង្កើតកម្មវិធីជួយដល់ក្មេងទុគ៌ត


Photo : Soeun KC

**សឿន**

សន្តិម៉ាថានៃព្រះសហគមន៍កាតូលិកកំពង់ចាម រៀបចំកម្មវិធីមួយចំនួនដើម្បីជួយដល់កុមារទុគិតនៅតាមដងផ្លូវ។ កម្មវិធីជួយដល់កុមារទុរគតិនេះរួមមានកម្មវិធីធ្វើអនាម័យ និងផ្តល់អាហារូបត្ថម្ភដោយមានអ្នកស្ម័គ្រចិត្តធ្វើការងារនេះចំនួន ៧រូប រួមមានលោកបូជាចារ្យ បងស្រី និងយុវជន។

កម្មវិធីនេះបានចាប់ផ្តើមដំណើរការកាលពីថ្ងៃទី ១៧ ខែមីនាមុននេះ ក្រោមគំនិតផ្តួចផ្តើម និងការធ្វើសហការរវាងព្រះសហគមន៍កាតូលិកកំពង់ចាម និងយុវជនស្ម័គ្រចិត្តមកពីប្រទេស បារាំង ឈ្មោះថា ឡេអូណា។

បើតាមការរៀបរាប់របស់ក្រុមសន្តិម៉ាថាឱ្យដឹងថា កុមារទាំងនោះ សុទ្ធសឹងជាក្មេងដើររើសអេតចាយ។ ឪពុកម្តាយរបស់ពួកគេ គឺជាអ្នកក្រីក្រ និងគ្មានដីដើម្បីចិញ្ចឹមជីវិត។ សព្វថ្ងៃ កុមារដែលបានជ្រើសរើស មានចំនួន ២១នាក់ មកពីភូមិពីរ គឺភូមិឆ្មាអើត ១៦នាក់ និងភូមិបឹងស្នាយ ៥នាក់។

ក្រុមបងស្រីបានឱ្យដឹងដែរថាសព្វថ្ងៃកុមារទាំងនេះ កំពុងសិក្សានៅបឋមសិក្សា ដែលមានចម្ងាយឆ្ងាយពីផ្ទះប្រមាណពី ២ ទៅ ៣គីឡូម៉ែត្រ។ ពេលខ្លះពេលចេញពីសាលារៀន ពួកគេគឺទៅរើសអេតចាយដើម្បីយកប្រាក់តិចតួចគ្រាន់ ទិញនំចំណី និងឱ្យទៅម្តាយគេដើម្បីទិញអង្ករ ហើយក៏ដើម្បីជួយដល់ជីវភាពគ្រួសារពួកគេ។

អ្នកស្ម័គ្រចិត្តធ្វើការងារក្នុងកម្មវិធីនេះ និយាយថា: "ទោះបីជាយើងមិនបានផ្តល់អ្វីជាដុំកំភួន ដល់កុមារទាំងនេះ ក៏ពិតមែន។ ប៉ុន្តែខ្ញុំក៏យល់ឃើញថាសកម្មភាពនេះជាការរួមចំណែកដ៏តូចមួយក្នុងការជួយពួកគេ ហើយនេះគឺជាសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ និងជាស្នាមញញឹមរបស់ព្រះអង្គដែលទ្រង់បានប្រទានសម្រាប់ពួកយើងដើម្បីធ្វើការងារបម្រើព្រះអង្គ។

# គុណតម្លៃនៃការស្តាប់

សិក្ខាសាលាស្តីអំពីការស្តាប់ យកគំរូព្រះ យេស៊ូបានប្រព្រឹត្តិទៅកាលពីថ្ងៃទី១-៣ ខែមេសា នៅឯព្រះសហគមន៍មណ្ឌលគិរី និងអ្នកចូលរួមមាន ៨០ នាក់ក្រោមការសម្របសម្រួលពីលោកផាន បូរ៉ា។

កញ្ញាជី សុភា តំណាងក្រុមយុវជនទាំង ៨ក្រុមក្នុងភូមិភាគកំពង់ចាមបាននិយាយថា សិក្ខាសាលានេះពិតជាជួយដល់ការងាររបស់ខ្ញុំច្រើន ពីព្រោះជាអ្នកសួរសុខទុក្ខអ្នកភូមិ យើងត្រូវធ្វើជាអ្នកស្តាប់ល្អ។ សុភាបន្តថា តាមអ្វីដែលខ្ញុំធ្លាប់ធ្វើពីមុនមកខ្ញុំពុំមែនជាអ្នកស្តាប់ល្អនោះទេ។អ្នកភូមិធ្លាប់ប្រាប់ខ្ញុំពីទុក្ខលំបាក។ ខ្ញុំបែរជាមិនយកចិត្តទុកស្តាប់ និងបានងាកទៅជជែកជាមួយអ្នកផ្សេងៗ។ នេះបានធ្វើឱ្យរូបខ្ញុំបាត់បង់នូវទំនុកចិត្តពីពួកគាត់។

លោកផាន បូរ៉ា តំណាងក្រុមប្រឹក្សាថ្នាក់ជាតិប្រចាំព្រះសហគមន៍ប្រទេសកម្ពុជារបស់ក្រុមសន្តវ៉ាំងសង់ ដឺប៉ូល បាននិយាយថា ការរៀបចំសិក្ខាសាលនេះ គឺជាទិសដៅរបស់ក្រុមប្រឹក្សា ថ្នាក់ជាតិដែលតម្រូវឱ្យរាល់សមាជិករបស់ខ្លួននៅក្នុងក្រុមអាចបំពេញចន្លោះខ្វះខាតរបស់ខ្លួនទាក់ទិនទៅនឹងការស្តាប់ដែលយកព្រះយេស៊ូជាគំរូ។

កញ្ញាហ៊ុន សេងណាយ សមាជិកក្រុមសន្តវ៉ាំងសង់ដឺប៉ូលក៏បាននិយាយថា នៅពេលយើងអាចធ្វើខ្លួនជាអ្នកស្តាប់ល្អដោយមានព្រះយេស៊ូជាគំរូនោះជំនឿរបស់យើងក៏នឹងរឹងមាំ។ នេះក៏នឹងធ្វើឱ្យជីវិតរបស់យើងកាន់តែប្រសើរឡើងផងដែរ។ ហើយអ្វីរឹតតែសំខាន់ជាងនេះទៅទៀតនោះ គឺថាយើងចេះយល់ពីផលប្រយោជន៍រួម។

សិក្ខាសាលានេះនឹងបន្តធ្វើជាមួយក្រុមសន្តវ៉ាំងសង់ដឺប៉ូល ពីថ្ងៃទី៧-៩ ខែមេសាម្តងទៀតនៅព្រះសហគមន៍ប៉ៃលិន ភូមិភាគបាត់ដំបង។

**សុខន**

## លោកអូលីវីយេ : យើងទទួលទឹក ទទួលពន្លឺ ដើម្បីកោតសរសើរព្រះជាម្ចាស់

នៅក្នុងពិធីបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (បុណ្យចម្លង) កាលពីខែមេសា លោកអូលីវីយេអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា: "នាប៉ុន្មានថ្ងៃមុនបុណ្យចម្លង យើងមានបទពិសោធន៍រួមជាមួយព្រះយេស៊ូដែលរងទុក្ខលំបាក តែយប់នេះទៀត យើងក៏មានបទពិសោធន៍អំពីជីវិតថ្មី ដែលព្រះអង្គប្រទានមកយើងដែរ"។

នៅក្នុងឱកាសនោះ លោកអភិបាលបានសង្កត់អត្ថន័យរបស់ទឹក និងពន្លឺ។ លោកបន្តថាព្រះយេស៊ូងើបពីទឹក មានសម្លេងមួយបន្លឺឡើងថា: "លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង"។ពេលព្រះអង្គសោយទិវង្គត គេបានចាក់ឆ្អឹងជំនីរបស់ព្រះអង្គពេលនោះមាន "ទឹកហូរចេញមក"។ លោកក៏បានបន្តថា បន្តិចទៀតមានបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹក គឺទឹកដែលប្រោសបងប្អូន ឱ្យទៅជាជនដ៏វិសុទ្ធ និងទៅជាប្រជារាស្ត្រនៃព្រះអង្គផ្ទាល់។ ចំពោះពន្លឺ លោកមានប្រសាសន៍ថា: "ព្រះជាម្ចាស់ញែកពន្លឺចេញពីភាពងងឹត"។ ព្រះអង្គបង្កើតពន្លឺមុនបង្កើតសត្វលោកទាំងអស់។ ដូច្នេះពន្លឺគឺជាប្រភពជីវិតគ្រប់យ៉ាង។ ក្នុងគម្ពីរព្រះយេស៊ូគឺជាសាក្សីនៃពន្លឺនេះ ព្រះអង្គបានប្រទាននូវពន្លឺឱ្យមនុស្សខ្វាក់ពីកំណើតបានទទួលពន្លឺ។ដូច្នេះព្រះយេស៊ូប្រទានទឹកឱ្យយើងលែងស្រេក និងប្រទានបន្លឺ ឱ្យយើងលែងដើរក្នុងភាពងងឹត។ អគ្គសញ្ញាជ្រមុជទឹក យើងរួមជាមួយព្រះគ្រីស្ត។ យើងទទួលទឹក និងទទួលពន្លឺដើម្បីកោតសរសើរព្រះជាម្ចាស់។

នាបុណ្យចម្លងឆ្នាំ២០១១ មានបងប្អូនប្រមាណជា ៣០០នាក់ ទូទាំងប្រទេស បានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងព្រះសហគមន៍កាតូលិក។ **វណ្ណា**

# ជំនួបស៊ីអែលស៊ី អន្តរជាតិដំបូងនៅកម្ពុជា

**ញឹប ពឿន**

មានការរៀបចំសិក្ខាសាលាស៊ីអែលស៊ី (CLC) មួយក្រោមប្រធានបទ "បុរស និងស្ត្រីត្រៀមខ្លួនជាស្រេចដើម្បីបម្រើអ្នកដទៃ" ដែលមានការចូលរួមពីអតីតនិស្សិតនៃព្រះសហគមន៍កាតូលិក និងក្រុមស៊ីអែលស៊ី កូរ៉េ ហុងកុង និងវៀតណាម កាលពីថ្ងៃទី៣០ ខែមេសា ដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១១ កន្លងទៅនេះ។

កម្មវិធីនេះបានប្រព្រឹត្តឡើងនៅមណ្ឌលព្រាបសរបស់ក្រុមសហជីវិនព្រះយេស៊ូ ឬក្រុមយេស៊ូអ៊ីត នៅភ្នំពេញថ្មី ហើយដែលបានផ្តួចផ្តើម និងរៀបចំឡើងដោយលោកបូជាចារ្យ យ៉ូហាន អេវ៉ាន់ អាស្លី និងលោកដាម៉ូ។ គោលបំណងរបស់សិក្ខាសាលានេះគឺដើម្បីកសាងមូលដ្ឋានគ្រឹះ និងជាជំហានដំបូងក្នុងការបង្កើតក្រុមស៊ីអែលស៊ី នៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត គឺដើម្បីឱ្យសិក្ខាកាមយល់ និងរកឱ្យឃើញ អំពីព្រះអំណោយទាន ដែលគេទទួលបានពីព្រះជាម្ចាស់ ។

អ្នកស្រីចាសមិន មកពីក្រុមស៊ីអែលស៊ី ហុងកុង



Photo : P. Sinay

មានប្រសាសន៍ថា : "ខ្ញុំមានការរីករាយយ៉ាងខ្លាំងក្នុងការស្នាក់នៅប្រទេសកម្ពុជា ហើយមានឱកាសបង្កើតមិត្តភាព។ ខ្ញុំសង្កេតឃើញថា ពួកយើងទាំងអស់មានភាពស្មោះត្រង់នឹងចែកចាយបទពិសោធន៍ជំនឿ និងជីវិតរវាងគ្នានិងគ្នាដោយឥតលាក់បាំង។

ចំណែកលោកទិត្យ សុភារ៉េន ជាសិក្ខាកាមម្នាក់បាននិយាយថា: "ខ្ញុំមានភាពសប្បាយរីករាយយ៉ាងខ្លាំងព្រោះបានជួបមិត្តភក្តិចាស់ៗ និងបានរៀនអំពីចំនុចស៊ីជម្រៅក្នុងការអនុវត្តផ្លូវវិញ្ញាណ"។

ស៊ីអែលស៊ី គឺជាក្រុមមួយ ដែលគ្រីស្តបរិស័ទរួបរួមគ្នានិងរិះគិតពីរបៀបរស់នៅ និងអនុវត្តលំហាត់ផ្លូវវិញ្ញាណរបស់សន្តអ៊ីញ៉ាស់ ដែលជាអ្នកបង្កើតក្រុមគ្រួសារសហជីវិនព្រះយេស៊ូ ក្នុងការស្វែងរកព្រះជាម្ចាស់ក្នុងគ្រប់កិច្ចការទាំងឡាយ តាមរយៈបទពិសោធន៍និងអំណោយទានដែលមាន។ ចំណែកសមាជិករបស់ស៊ីអែលស៊ីទាំងអស់ គឺជាគ្រហស្ថ។

# ក្រុមសន្តអេជីឌីអូតំបន់អាស៊ីប្រជុំស្វែងរកគន្លឹះអភិវឌ្ឍក្រុម

កិច្ចប្រជុំស្តីពីការរងទុក្ខលំបាករបស់ព្រះយេស៊ូគ្រីស្តបានដំណើរការទៅពីថ្ងៃទី២០-២៤ ខែមេសា នៅឯប្រទេសហ្វីលីពីនដែលមានអ្នកចូលរួមប្រមាណសរុប ១០០នាក់ មកពីបណ្តាលប្រទេសក្នុងតំបន់អាស៊ីនៃក្រុមសន្ត អេជីឌីអូ។

លោកជិនសាង ជាប្រធានក្រុមសន្តអេជីឌីអូនៃព្រះវិហារព្រះកុមារយេស៊ូព្រះសហគមន៍ប្រទេសកម្ពុជា បានពន្យល់ថា កិច្ចប្រជុំនេះផ្តល់គន្លឹះដោះស្រាយនៅលើជំហានអភិវឌ្ឍសកម្មភាពរបស់ក្រុមដើម្បីឱ្យកាន់តែមានភាពល្អប្រសើរ។ លោកក៏បានលើកឡើងថា ជាធម្មតាក្រុមសន្តអេជីឌីអូ ក្នុងព្រះសហគមន៍នៅប្រទេសកម្ពុជា តែងមានសកម្មភាពដូចជាការចុះបង្រៀនអក្សរ និងការធ្វើអនាម័យឱ្យដល់ក្មេងៗ និងអ្នកភូមិ ព្រមទាំងសួរសុខទុក្ខចាស់ជរានៅតាម គេហដ្ឋានរបស់ពួកគាត់។ ហើយទង្វើទាំងនេះគឺមានដូចគ្នាទាំងអស់នៅគ្រប់ក្រុមសន្តអេជីឌីអូនៅតាមបណ្តាប្រទេសនានា។

**សុខន**

# ពិធីបុណ្យហែស្លឹកនៅព្រះសហគមន៍កាតូលិកក្រុងព្រះសីហនុ

ពិធីបុណ្យហែស្លឹក ដោយរួមមានការសម្តែងរឿងព្រះយេស៊ូរងទុក្ខលំបាក និងសោយទិវង្គត និងការថ្វាយអភិបូជា ត្រូវបានប្រារព្ធធ្វើឡើងនៅព្រះសហគមន៍កាតូលិកក្រុងព្រះសីហនុ កាលពីថ្ងៃទី១៧ មេសា កន្លងទៅ ដោយមានការចូលរួមពីលោកអភិបាលអ៊ីវ រ៉ាមូស លោកបូជាចារ្យ បុព្វជិត បព្វជិតា គ្រីស្តបរិស័ទ និងភ្ញៀវកិត្តិយសយ៉ាងច្រើនកុះករ ប្រមាណជា ១៥០នាក់។



Photo : P. Samphy

លោកបូជាចារ្យស្រ៊ី ប្រាម៉ុង វីរៈជ័យ ទទួលខុសត្រូវព្រះសហគមន៍តំបន់ក្រុងព្រះសីហនុ មានប្រសាសន៍ថា ពិធីនេះធ្វើឡើងក្នុងគោលបំណងរំឭកអំពីព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ប៉ុន្តែព្រះអង្គមិនមែនចូលទៅធ្វើជាស្តេច។ ប៉ុន្តែព្រះអង្គសុខចិត្តរងទុក្ខលំបាក និងលះបង់ជីវិត។ ដូច្នេះយើងជាគ្រីស្តត្រូវហ៊ានដើរទៅរកទុក្ខលំបាកក្នុងជីវិតដោយរួមជាមួយព្រះអង្គ។ លោកបូជាចារ្យបន្តថា កម្មវិធីឆ្នាំនេះប្លែកដោយមានការសម្តែងរឿង ដែលអាចឱ្យគ្រីស្តបរិស័ទឆាប់ចងចាំជីវិតព្រះយេស៊ូ។ បើអានព្រះគម្ពីរ រយៈពេល ៤៥នាទី គឺយូរណាស់ដែលឱ្យអ្នកស្តាប់ធុញទ្រាន់។

លោកបូជាចារ្យ ដេនីស យ៉ែរីយ៉េ នៅព្រះសហគមន៍កាតូលិកក្រុងព្រះសីហនុ បានមានប្រសាសន៍ថា រឿងនេះបង្ហាញអំពីព្រះយេស៊ូគ្រីស្តរងទុក្ខលំបាកដោយមិនមានខុសអ្វីសោះ។ ដូច្នេះព្រះយេស៊ូតែងគង់នៅជាមួយអ្នកដែលរងទុក្ខលំបាក។

លោកប៊ុន ថា អាយុ ២៥ឆ្នាំ ជាអ្នកចូលរួមនិយាយថា : "រឿងព្រះយេស៊ូរងទុក្ខលំបាកបង្ហាញពីព្រះអង្គលះបង់ជីវិតសម្រាប់ពិភពលោកទាំងមូល"។ អ្នកស្រីណាច ផាត់ ជាគ្រីស្តបរិស័ទចូលរួម មានប្រសាសន៍ថា ពិធីបុណ្យហែស្លឹកនេះ និងមានការសម្តែងរឿងធ្វើឱ្យយើងឃើញព្រះយេស៊ូគ្រីស្តដោះបាបសម្រាប់ពិភពលោក។ ចំណែកយុវជនជា ប៊ុនហួរ ជាគ្រីស្តបរិស័ទ និងបានចូលសម្តែងជាតួអង្គមហាបូជាចារ្យក្នុងរឿងបាននិយាយថា ព្រះអង្គសោយទិវង្គតជារឿងប្លែកសម្រាប់លោក។ ហើយការសម្តែងរឿងបានធ្វើឱ្យលោករឹតតែមានជំនឿ និងស្គាល់ច្បាស់អំពីព្រះបន្ទូលព្រះអង្គនៅក្នុងជីវិតរស់នៅ។

**សំភី**

# គីកេ : "ព្រះជាម្ចាស់មិនត្រូវការព្រះវិហារធំទេ តែត្រូវការចិត្តរបស់យើង"

**លី សុវណ្ណា**

ព្រះវិហារមួយខ្នងក្នុងភូមិអូរតាពុក នៅឯខេត្តប៉ៃលិនបានសម្ពោធឱ្យប្រើប្រាស់កាលពីថ្ងៃទី១ ខែឧសភាកន្លងទៅ ក្រោមអធិបតីភាពនៃលោកគីកេ ហ្វីការេដូ អភិបាលព្រះសហគមន៍ភាគបាត់ដំបង។ ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់លោកអភិបាលនៃព្រះសហគន៏ភូមិភាគកំពង់ចាម លោកប្រធានមន្ទីរធម្មការ និងសាសនាខេត្ត បព្វជិត បព្វជិតា គ្រីស្តបរិស័ទប្រមាណជាង ១000នាក់ ដែលមកពីតំបន់ផ្សេងៗ មានកំពង់ធំ សៀមរាប បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ោយប៉ែត និងតំបន់ប៉ៃលិន។

លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង គីកេ ហ្វីការេដូ មានប្រសាសន៍ថា យើងមានអំណរសប្បាយជួបជុំគ្នានៅជុំវិញព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ហើយដោយមានព្រះហារថ្មីដែលយើងសម្ពោធនៅថ្ងៃនេះ។ ប៉ុន្តែព្រះជាម្ចាស់ពុំត្រូវការព្រះវិហារធំទេ ព្រះអង្គត្រូវការចិត្តរបស់យើង គឺចិត្តដែលប្រព្រឹត្តិតាមព្រះហឫទ័យរបស់ព្រះអង្គ ចិត្តពោរពេញទៅដោយការស្រឡាញ់មេត្តាករុណា សន្តិភាព ចេះសម្រុះសម្រួល និងបម្រើអ្នកដទៃ។ ចិត្តល្អ នាំឱ្យយើងមានអំណរសប្បាយ បានជិតស្និទ្ធជាមួយព្រះអង្គ។ លោកបញ្ជាក់ថា បើយើងមិនកែប្រែចិត្តគំនិត ហើយដើរតាមមាគ៌ារបស់ព្រះអង្គទេ ព្រះវិហារថ្មីនឹងមិនមានសារៈសំខាន់ឡើយ ។លោកអភិបាលបានបន្តថា ព្រះបន្ទូលថ្ងៃនេះ ព្រះជាម្ចាស់បានប្រទានឱ្យយើងនូវសេចក្តីសុខសាន្ត បេសកកម្ម និងអំណរសប្បាយ។

លោកយ៉ូសេ ហ៊ីលឌី បាណៃណាល់ (តូតែត) ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ប៉ៃលិនមានប្រសាសន៍ថា ព្រះវិហារថ្មីនេះមានឈ្មោះថា "ព្រះវិហារមេត្តាករុណានៃព្រះជាម្ចាស់ **(The Sacred Heart of Jesus)**" ខេត្តប៉ៃលិន។ ព្រះសហគមន៍នេះមានសមាជិកប្រមាណជា១00នាក់ ទាំងគ្រីស្តបរិស័ទ និងអ្នកកំពុងស្វែងយល់។ លោកក៏បានបន្តថា ព្រះសហគមន៍កាតូលិកប៉ៃលិនមានសកម្មភាពផ្សេងៗជាច្រើនដូចជាការអប់រំបន្តជំនឿ ការទទួលអ្នកជំងឺ ការអប់រំចំណេះទូទៅ ដូចជាការបង្រៀនភាសាអង់គ្លេស ការបង្រៀនកុំព្យូទ័រ ព្រមទាំងការឧបត្ថម្ភសិស្សសាលារៀននានា។

លោកសំ អ៊ុំពៅ ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តប៉ៃលិន មានប្រសាសន៍ថា ព្រះវិហារនេះគឺបានចំណាយពេលច្រើន ដើម្បីឱ្យបានត្រឹមត្រូវតាមច្បាប់ និងបែបបទរដ្ឋបាល។ មន្ទីរគឺគ្រាន់តែជាអ្នកសម្របសម្រួលការអនុញ្ញាត គឺក្រសួងធម្មការ និងសាសនាជាអ្នកសម្រេច។ ពេលនេះព្រះវិហារថ្មី គឺមានច្បាប់ត្រឹមត្រូវ និងស្របច្បាប់។ នៅក្នុងខេត្តនេះ មានព្រះវិហារកាតូលិកតែមួយគត់។ ក្នុងពិធីនេះ លោកបានសំណូមពរឱ្យអ្នកណែនាំព្រះសហគមន៏មានទំនាក់ទំនងល្អជាមួយមន្ទីរផងដែរ។

ព្រះសហគមន៏ប៉ៃលិននេះបានកើតឡើងដោយគ្រីស្តបរិស័ទពីបាត់ដំបង និងគ្រីស្តបរិស័ទពីជំរំជាយដែនមួយចំនួនតូចដែលមកប្រកបរបរនៅប៉ៃលិន។ នៅឆ្នាំ២00២ ក៏ចាប់ផ្តើមមានការអប់រំជំនឿដល់គ្រីស្តបរិស័ទដែលជ្រមុជទឹកហើយដើម្បីទទួលអគ្គសញ្ញាលាបថ្ងាស។ នៅឆ្នាំ២00៦ មាន ៧នាក់បានទទួលព្រះកាយ និងអគ្គសញ្ញាលាបថ្ងាស។ នៅឆ្នាំ២00៧ មានយុវជនចំនួន ៨នាក់ ទទួលអគ្គសញ្ញាជ្រមុជទឹក។ នៅឆ្នាំ២00៨ចាប់ផ្តើមការសាងសង់ព្រះវិហារ និងរួចរាល់នៅឆ្នាំ២០១០។ នៅឆ្នាំ២0១១នេះ មានយុវជនចំនួន ៦នាក់ ទទួលអគ្គសញ្ញាជ្រមុជក្នុងឱកាសបុណ្យចម្លង។






Photo : L. Sovanna

# ជីវភាពមិនមែនជាឧបសគ្គក្នុងការក្លាយកវីដែលមានទឹកដៃឆ្នើម

**អ៊ឹម សុខន**



Photo : JS

អ្នកស្រីខុង ណារី មានកំណើតនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៦០ នៅសង្កាត់បឹងសាឡាង ទីក្រុងភ្នំពេញ។ អ្នកស្រីមានកម្រិតវប្បធម៌ត្រឹមថ្នាក់ទី៩ចាស់ ដែលស្មើនិងថ្នាក់ទី៣បច្ចុប្បន្ន។

ក្រោយពីរូបអ្នកស្រីបានរៀបអាពាហ៍ពិពាហ៍នឹងស្វាមីជាពលទាហានរួច នៅក្រោយឆ្នាំ១៩៩០ ក្រុមគ្រួសាររបស់ អ្នកស្រីបានប្តូរទីលំនៅពីទីក្រុងភ្នំពេញទៅរស់នៅឯស្រុកអង្គស្នួល ខេត្តកណ្តាល គឺដោយសារកត្តាជីវភាព ហើយម្យ៉ាងអ្នកស្រីគ្មានចេះអ្វីក្រៅពីធ្វើស្រែចំការ។

ពីឆ្នាំ២០០០ រហូតដល់ឆ្នាំ ២០០៧ អ្នកស្រីបានចូលបម្រើការងារផ្នែកគម្រោងអភិវឌ្ឍន៍សហគមន៍ស្រុកអង្គស្នួលនៃអង្គការជេអេសស៊ុជាបុគ្គលិកសមាគមនារី ភូមិទន្លាប់ ឃុំព្រៃពួច ខេត្តកណ្តាល។

ទោះបីជារូបអ្នកស្រីមានការលំបាកក្នុងជីវភាព ក៏អ្នកស្រីគឺជាកវីនិពន្ធកំណាព្យម្នាក់ ដែលមានទឹកដៃគាប់ប្រសើរ។

អ្នកស្រីខុង ណារី បានរៀបរាប់ថា ដំបូងខ្ញុំពុំដឹងថា ខ្លួនខ្ញុំអាចសរសេរកំណាព្យបាននោះទេ។ ប៉ុន្តែនៅពេលដែលម្តាយឪពុកខ្ញុំលែងលះគ្នា។ ហើយខ្ញុំមើលឃើញក្មេងដទៃមានឪពុកម្តាយ។ ពេលនោះអារម្មណ៍ជាកូនក្មេង ក៏រៀបរាប់អំពីអារម្មណ៍នឹកនាចង់ឃើញ និងចង់មានដូចគេ។ បើនិយាយអំពីការសរសេរពេលនោះ មានប្រមាណជា ២០០ទំព័រ តែសំណៅទាំងនោះ ត្រូវបានបាត់បង់នៅអំឡុងពេលជំនាន់ប៉ុលពតអស់ទៅហើយ។

សម្រាប់ស្នាដៃដែលអ្នកស្រីបានសរសេរ ហើយនិពន្ធកំណាព្យពីឆ្នាំ២០០៤ មានជាង ៧០ អត្ថបទកំណាព្យក្នុងនោះ មាន អនិច្ចាអ្នកស្រែ គុណម្តាយ កំណាព្យអ្នកស្រែ កោះកុងក្នុងដួងចិត្តខ្ញុំ ពិធីបុណ្យនៅ បាត់ដំបង...។ ក្រៅពីនេះចម្រៀងបាន ៥បទ រឿងខ្លី ៣ និងរឿងកំប្លែងខ្លីបាន ៦រឿង។

អ្នកស្រីខុង ណារី បានជាប់ចំណាត់ថ្នាក់លេខ១ លើអត្ថបទកំណាព្យ"ត្នោតមាស" និងទទួលរង្វាន់លើកទឹកចិត្តពីលោកបូជាចារ្យអូមែរជាអគ្គនាយកព្រឹត្តិបត្រអ្នកនាំសារ ប្រចាំការិយាល័យផ្សព្វផ្សាយព័ត៌មាន ព្រះសហគមន៍កាតូលិក កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៥។ មិនត្រឹមតែប៉ុណ្ណោះអ្នកស្រីបាននិពន្ធ និងសូត្រកំណាព្យ "ទំនួញកុមាររងគ្រោះដោយសារមីន" ថ្វាយព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី នាឱកាសព្រះអង្គយាងព្រះសណ្តាប់របាយការណ៍ ស្តីអំពីមីននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការនៅបន្ទាយព្រាប ភូមិត្រពាំងវែង ឃុំឆក់ឈើនាងនៃស្រុកអង្គស្នួល កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៤។

បន្ទាប់មកទៀត អ្នកស្រីបានទទួលរង្វាន់ លើកទឹកចិត្តពីវិទ្យាល័យហ៊ុន សែនអង្គស្នួលនៅក្នុងខេត្តកណ្តាល ដោយបាននិពន្ធកំណាព្យជូនឱ្យវិទ្យាល័យមានចំណងជើង ថា "ឱ! អ្នកមានគុណ" នាថ្ងៃទី៥ ខែមេសា នៅឆ្នាំ២០០៥។

## ព្រះសហគមន៍កាតូលិកប្រារព្ធបុណ្យគោរពមរណសាក្សី



Photo : L. Sovanna

ព្រះសហគមន៍នៅប្រទេសកម្ពុជា ប្រារព្ធបុណ្យមរណសាក្សីនៅកម្ពុជា កាលពីថ្ងៃទី៧ ខែឧសភាកន្លងទៅ ដោយមានការចូលរួមពីគ្រីស្តបរិស័ទ បព្វជិត បព្វជិតា លោកអភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញ និងកំពង់ចាម នៅដីមរណសាក្សី (ដីនៃក្តីសង្ឃឹម) ភូមិតាំងគោក ឃុំច្រនៀង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

លោកអេមីល ដេតម្ប អតីតអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា នៅឆ្នាំ១៩៧៥ មនុស្សជាច្រើនដែលត្រូវជម្លៀសពីទីក្រុងត្រូវបានសម្លាប់ ក្នុងនោះមានទាំងលោកអភិបាល និងគ្រីស្តបរិស័ទកាតូលិកផងដែរ។ លោកបន្តថា នៅថ្ងៃនេះ យើងជួបជុំគ្នារំឭកដល់បងប្អូនរបស់យើងដែលបានស្លាប់ ដើម្បីប្រទេសជាតិ និងដោយសារជំនឿ។

ចំណែកលោកអូលីវីយេអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា គំរូរបស់មណរសាក្សីជា កម្លាំងរបស់យើង។ បន្តិចទៀតយើងនឹងធ្វើអង្កេតដើម្បីឱ្យព្រះសហគមន៍ ទទួលស្គាល់មរណសាក្សីទាំងនោះជាផ្លូវការ។

ដោយឡែកនៅព្រះសហគមន៍ស្វាយស៊ីសុផុន ក៏បានប្រារព្ធពិធីនេះក្រោមអធិបតីភាពលោកគីកែអភិបាលព្រះសហគមន៍ភូមិបាត់ដំបងដើម្បីរំឭកដល់ លោកទេពអ៊ឹម សុថា អតីតអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ដែលពួកខ្មែរក្រហមសម្លាប់នៅភូមិបត់ត្រង់ ឃុំបត់ត្រង់ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

សម្តេចប៉ាបយ៉ូហានប៉ូលទី២ បានកំណត់ថ្ងៃទី៧ ឧសភា ជាថ្ងៃបុណ្យមរណសាក្សីនៅកម្ពុជា។ **វណ្ណា**

# ការសាយភាយនៃថាមពលអគ្គិសនីដើរដោយនុយក្លេអ៊ែរ

**ជាត សំភី**



Photos : DR

រោងចក្រនុយក្លេអ៊ែរ គឺជាមណ្ឌលឧស្សាហកម្មមួយដែលប្រើប្រាស់ធាតុគីមីវិទ្យុសកម្មដូចជា អ៊ុយរ៉ានីញ៉ូម ឬភ្លូតូនីញ៉ូម ដើម្បីបង្កើតកម្តៅ ដែលមួយផ្នែកត្រូវបានបំប្លែងទៅជាចរន្តអគ្គិសនី។

មណ្ឌលថាមពលអគ្គិសនីនុយក្លេអ៊ែរ គឺត្រូវបានផ្សំឡើយដោយរ៉េអាក់ទ័រនុយក្លេអែរមួយ ឬច្រើន ដែលថាមពលអគ្គិសនីរបស់វា គឺប្រែប្រួលពីប៉ុន្មានមេហ្គាវ៉ាត់ទៅដល់ច្រើនជាង ១៥០០មេហ្គាវ៉ាត់។

ថាមពលអគ្គិសនីដែលផលិតបានពីនុយក្លេអ៊ែរពិភពលោក បានរីកចម្រើនយ៉ាងឆាប់រហ័ស គឺកើនពីមួយជីហ្គាវ៉ាត់នៅឆ្នាំ១៩៦០ រហូតដល់១០០ ជីហ្គាវ៉ាត់នៅដំណាច់ទសវត្សរ៍ឆ្នាំ១៩៧០ និង ៣០០ ជីហ្គាវ៉ាត់នៅដំណាច់ទសវត្សរ៍ឆ្នាំ១៩៨០។ បន្ទាប់ពីនេះ សមត្ថភាពនៃថាមពលអគ្គិសនីនុយក្លេរអ៊ែរពិភពលោកបានកើនឡើងដោយយឺតៗ គឺដល់ត្រឹម ៣៦៦ជីហ្គាវ៉ាត់នៅឆ្នាំ២០០៥ដោយសារតែកម្មវិធីនុយក្លេអ៊ែររបស់ប្រទេសចិន។ ប៉ុន្តែគឺច្រើនជាងពីរភាគបីនៃមណ្ឌលនុយក្លេអ៊ែរ ដែលស្នើឡើងបន្ទាប់ពីខែមករា ឆ្នាំ១៩៧០ ត្រូវបានលុបចោល។

ថ្លៃដើមសេដ្ឋកិច្ចបានកើនឡើងដោយសាររយៈពេលនៃការស្ថាបនាកាន់តែវែងឡើង និងការធ្លាក់ចុះតម្លៃនៃឥន្ធនៈផូស៊ីល បានធ្វើឱ្យថាមពលនុយក្លេអែរកាន់តែមានការប្រកួតប្រជែងតិចទៅៗនៅទសវត្សរ៍ឆ្នាំ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០។

ម្យ៉ាងវិញទៀតនៅក្នុងប្រទេសជាច្រើនសាធារណៈមតិតែងតែព្រួយបារម្ភនឹងការប្រថុយប្រថាននៃរោងចក្រនុយក្លេអែរ និងបញ្ហាសំណល់វិទ្យុសកម្មដែលរឿងនេះនាំទៅដល់ការបោះបង់ចោលនូវថាមពលនុយក្លេអ៊ែរ។

មានមហន្តរាយយ៉ាងធំកើតឡើងលើមណ្ឌលនុយក្លេអ៊ែរជំនាន់ទីមួយនៃអតីតសហភាពសូវៀតពោល គឺការផ្ទុះឡើងនៃរោងចក្រឆេណូប៊ីល នៅសហភាពសូវៀតថ្ងៃទី២៦មេសាឆ្នាំ១៩៨៦។

ចំណែកគ្រោះថ្នាក់សំខាន់បីទៀតបានកើនឡើងផងដែរ ដូចជាការឆាបឆេះមណ្ឌលសាឡាហ្វៀនៅប្រទេសអង់គ្លេសនៅឆ្នាំ១៩៥៧ គ្រោះថ្នាក់នៅឯមណ្ឌលនុយក្លេអ៊ែរ ស្រ៊ីម៉ាយអាយឡែននាឆ្នាំ១៩៧៩ នៅសហរដ្ឋអាមេរិក ព្រមទាំងគ្រោះថ្នាក់នុយក្លេអ៊ែរនៅមណ្ឌលហ្វូគូស៊ីម៉ា ប្រទេសជប៉ុន នៅឆ្នាំ២០១១នេះ ដោយសារគ្រោះរញ្ជួយផែនដី។

នៅឆ្នាំ២០០៩ រ៉េអាក់ទ័រនុយក្លេរអ៊ែរ ៤៣៩ ក៏បានដំណើរការនៅក្នុង ៣១ប្រទេសផ្សេងៗគ្នា នៅលើពិភពលោក ដែលផលិតថាមពលបានរហូតដល់ ៣៧០ ជីហ្គាវ៉ាត់ ដែលត្រូវប្រមាណជា ១៤% នៃថាមពលអគ្គិសនីពិភពលោក។

ប៉ុន្តែមហន្តរាយនៃរោងចក្រអគ្គិសនី ឆេណូប៊ីល (Tchenobyl) នៅទសវត្សរ៍ឆ្នាំ១៩៨០ ក៏បាននាំដល់ការពន្យាពេលនៃការសាងសង់រ៉េអាក់ទ័រថ្មីៗជាច្រើន។ ហើយការធ្លាក់ចុះនៃតម្លៃប្រេងនៅក្នុងទស្សវត្សរ៍ទី៩០ បានពង្រឹងនិន្នាការធ្លាក់ចុះនេះ គឺការស្ថាបនាកាន់តែតិចទៅនៃរោងចក្រនុយក្លេអ៊ែរនៅក្នុងពិភពលោកទាំងមូល។

ស្របពេលជាមួយគ្នានេះដែរ មណ្ឌលថាមពលអគ្គិសនីនុយក្លេអ៊ែរនានាកាត់តែចាស់ទៅ។នៅក្នុងឆ្នាំ២០០៦ រ៉េអាក់ទ័រនុយក្លេអ៊ែរ ភាគច្រើនមានអាយុចន្លោះពី១៥-៣៦ឆ្នាំ។ រ៉េអាក់ទ័រចំនួន ៧ មានអាយុពី៣៧ ទៅ ៤០ឆ្នាំ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ ការកើនឡើងនៃថ្លៃថាមពលដូចជាថាមពលត្បូងថ្មនិងតម្លៃឧស្ម័ន និងនាំឱ្យផែនដីឡើងកម្តៅ ក៏បាននាំឱ្យមានចលនាច្រាសត្រឡប់មកវិញក្នុងការសាងសង់។

ប្រទេសហ្វាំងឡង់ចាប់ផ្តើមរ៉េអាក់ទ័រមួយនៅតំបន់អូលគីលូអូតូ នៅឆ្នាំ២០០៣ និងការស្ថាបនារ៉េអាក់ទ័រថ្មីមួយទៀតដែលកំពុងតែដំណើរការនៅតំបន់ន័រម៉ងឌី ប្រទេសបារាំង បន្ទាប់ពីមានសេចក្តីសម្រេចនៅឆ្នាំ២០០៥។



### កាលប្រវត្តិខ្លះៗ អំពីការសាងសង់

ចាប់តាំងពីថ្ងៃទី២០ ធ្នូ ឆ្នាំ១៩៥១ មណ្ឌលនុយក្លេអែរទីមួយត្រូវបានដាក់ឱ្យដំណើរការនៅសហរដ្ឋអាមេរិក។ នៅថ្ងៃទី២៧ មិថុនា ឆ្នាំ១៩៥៤ មណ្ឌលនុយក្លេរអ៊ែរត្រូវបានចាប់សាងសង់នៅទីក្រុងអូបនីនស្គ័ សហភាពសូវៀត ជាមួយនឹងសមត្ថភាពផលិតអគ្គិសនីបាន ៥មេហ្គាវ៉ាត់។ មណ្ឌលនុយក្លេអ៊ែរបន្តបន្ទាប់ មានដូចជា មណ្ឌលម៉ាកគូល នៅតំបន់ប្រូវ៉ង់ ប្រទេសបារាំងត្រូវបានស្ថាបនាឡើងនៅថ្ងៃ៧ មករា ឆ្នាំ ១៩៥៦ និងមណ្ឌលសេឡាហ្វៀនៅចក្រភពអង់គ្លេសនៅឆ្នាំ១៩៥៦...។

នុយក្លេអ៊ែរគឺជាបច្ចេកវិទ្យាដែលធ្វើឱ្យរស់រវើកនូវជម្លោះ និងការតស៊ូមតិយ៉ាងតឹងតែង។ ប៉ុន្តែខ្សែសង្វាក់នុយក្លេអ៊ែរផលិតថាមពលបានតែ១៤,៨% នៃថាមពលអគ្គិសនីនៅក្នុងពិភពលោកនៅក្នុងឆ្នាំ២០០៦។



Photo : Rithy

# កម្ពុជាបើកទ្វារវប្បធម៌នៅរៀងរាល់ល្ងាចថ្ងៃសុក្រ នៅសាលសន្និសីទចតុមុខ

**ខាន់ ភីរម្យ**

សហប្រធាននៃក្រុមការងារអភិវឌ្ឍន៍វិស័យទេសចរណ៍បានអះអាងថា នៅរៀងរាល់ល្ងាចនាថ្ងៃសុក្រ ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ដែលចាប់អារម្មណ៍ នឹងផ្ទាំងទស្សនីយភាពវប្បធម៌ និងសិល្បៈខ្មែរអាចចូលទស្សនានៅសាលសន្និសីទចតុមុខ។

លោកហូវណ្ណី សហប្រធានក្រុមការងារអភិវឌ្ឍន៍វិស័យទេសចរណ៍មានប្រសាសន៍ថា ផ្ទាំងទស្សនីយភាពវប្បធម៌ខ្មែរសម្តែងតាមរយៈរបាំនឹងត្រូវសម្តែងជូនភ្ញៀវទេសចរណ៍ទស្សនាចាប់ពីម៉ោង ៧យប់ តទៅនៅសាលសន្និសីទចតុមុខ។

លោកបានឱ្យដឹងដែរថា ការសម្តែងនេះរៀបចំឡើងដោយនាយកដ្ឋានសិល្បៈ និងទស្សនីយភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក្រោមកិច្ចសហការជាមួយនិងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា ដើម្បីលើកស្ទួយនូវវិស័យសិល្បៈវប្បធម៌ខ្មែរ និងទាក់ទាញទេសចរបរទេសឱ្យមកទស្សនា។ លោកក៏បញ្ជាក់ថា: "នេះគឺជាផលិតផលថ្មីដែលយើងផលិតឡើងដើម្បីផ្តល់ជម្រើសដល់ភ្ញៀវទេសចរណ៍ និងជាការឃោសនាពីវប្បធម៌ និងទីផ្សារទេសចរណ៍របស់កម្ពុជា ហើយវាក៏ជាវេទិកាមួយ ដែលនឹងជួយ និងបង្កើតអាជីពការងារឱ្យដល់ សិល្បករ និងសិល្បការិនីខ្មែរផងដែរ"។

រាល់ទស្សនីយភាពនេះមានការចូលរួមសម្តែងដោយក្រុមសិល្បករ និងសិល្បការិនីខ្មែរចំនួនប្រមាណ ៥០នាក់។

កម្មវិធីនៃការសម្តែង គឺមានរបាំបុរាណ របាំប្រពៃណី និងរបាំសម័យផ្សេងៗ។ អ្នកដែលអាចចូលរួម គឺត្រូវទិញសំបុត្រ ដោយតម្លៃ ១0000រៀល សម្រាប់ជនជាតិខ្មែរ ៧ដុល្លារ ដល់១០ដុល្លារ សម្រាប់ភ្ញៀវទេសចរណ៍អន្តរជាតិ។

លោកហូ វណ្ណី ក៏បានបន្តឱ្យដឹងទៀតថា ផ្ទាំងទស្សនីយភាពនេះ បានចាប់ផ្តើមតាំងតែពីខែមីនា ឆ្នាំ២០១១មកម្ល៉េះ។ តែទោះបីជាយ៉ាងណាក៏ដោយ លោកបានអះអាងថា ដើម្បីនិរន្តរភាពការសម្តែងនេះ គឺគួរតែធ្វើទីផ្សារឱ្យច្រើនបន្ថែមទៀត។ លោកបន្តទៀតដែរថា មកដល់ពេលនេះ ការឃោសនា និងការធ្វើទីផ្សារសម្រាប់កម្មវិធីសម្តែងនេះនៅមិនទាន់បានទូលំទូលាយនៅឡើយទេ នាខណៈដែលផ្ទាំងទស្សនីយភាព នេះបានត្រូវចិត្តដល់ជនបរទេស គឺពិសេសភ្ញៀវទេសចរណ៍លោកខាងលិចដែលមានការចាប់អារម្មណ៍យ៉ាងច្រើន។

## អំណាន

### កូលាបប៉ៃលិន



ជាប្រលោមលោកបែបមនោសញ្ចេតនា ដែលរៀបរាប់ពីស្នេហារបស់កម្មករកម្លោះ និងចៅហ្វាយក្រមុំ។ រឿងនេះគឺជាអក្សរសិល្ប៍ទំនើប ដែលគេលើកយកមកសិក្សា និងវិភាគនៅក្នុងកម្មវិធីសិក្សា។

ក្រោយពីឪពុកស្លាប់ទៅ ចៅចិត្រទៅធ្វើការជាកម្មករជីកត្បូងនៅផ្ទះលោកហ្លួងរតនាសម្បត្តិ នៅឯបរប៉ៃលិន។ លោកហ្លួងមានកូនក្រមុំតែម្នាក់គត់ គឺឈ្មោះ ឃុន នារី។ ឃុន នារី មានរូបឆោមល្អឯកដាច់គេ តែនាងមានឫកពារឆ្មើងឆ្មៃ និងប្រកាន់ខ្លួន។ គ្រាន់តែឃើញនារីភ្លាមចៅចិត្រក៏លួចចាប់ចិត្តស្នេហាលើនាង។ តើស្នេហារបស់ចៅចិត្រអាចទៅរួចទេ? បើនារីជាកូនស្រីអ្នកមាន និងថែមទាំងជាចៅហ្វាយស្រីរបស់ខ្លួនទៀតផងនោះ?

ក្រៅអំពីសេចក្តីស្នេហានេះ សាច់រឿងក៏បានរៀបរាប់ផងដែរ ពីជីវិតខិតខំប្រឹងប្រែងតស៊ូ ឧស្សាហ៍ព្យាយាម និងភាពសុចរិតស្មោះត្រង់របស់ចៅចិត្រ ដែលជាក្មេងកំព្រា។

កូលាបប៉ៃលិននិពន្ធដោយលោកញ៉ុក ថែម និងបោះពុម្ពផ្សាយដោយក្រសួងអប់រំ។

### លិខិតដែលមិនបានផ្ញើ




មានភាពសម្បូរបែបទាំងខាងសេចក្តីស្រឡាញ់របស់ម្តាយចំពោះកូននិងការរស់នៅជាប្តី-ប្រពន្ធ។

មិនតែប៉ុណ្ណោះវាជារឿងមួយឆ្លុះបញ្ចាំងពីការធ្វើបដិវត្តរបស់ស្ត្រីរុស្ស៊ី ដែលទាមទារចេញទៅរៀនបន្តនៅសកលវិទ្យាល័យ និងចូលរួមសកម្មភាពផ្សេងៗ ក្នុងសង្គម ក្នុងខណៈដែលប្តីរបស់ខ្លួនមិនអនុញ្ញាតឱ្យទាល់តែសោះ។

ក្នុងលិខិតទាំងនេះ ហ្គាលីយ៉ាក៏បានសរសេររំឭកឡើងវិញនូវរាល់អនុស្សាវរីយ៍រំភើប និងឈឺចាប់រវាងនាង និងប្តីនាង ឈ្មោះអ៊ីស្តៃខ្មែរ។ ពួកគេបានជួបគ្នានៅពេលរាត្រីស្រមោស ហើយក៏បានស្រឡាញ់គ្នា។ សេចក្តីស្នេហាបាននាំមកឱ្យមនុស្សនូវសេចក្តីរីករាយ និងកម្លាំង ដ៏ខ្លាំងក្លា។ ប៉ុន្តែភាពផ្អែមល្ហែមនេះមានតែមួយរយៈប៉ុណ្ណោះ ពួកគេក៏ដឹងថា គំនិត និងមនោសញ្ចេតនាពួកគេខុសពីគ្នាស្រឡះ។ ទីបំផុតចំណងស្នេហ៍របស់ពួកគេឈានទៅរក ការចែកផ្លូវដោយបន្សល់ទុកនូវកូនពីរនាក់ដែលកំព្រាឪពុក។

លិខិតដែលមិនបានផ្ញើ គឺជាប្រលោមលោករុស្ស៊ី ដែលនិពន្ធដោយ អាដែនគូទូយ និងត្រូវបានធ្វើការប្រែសម្រួលជាភាសាខ្មែរ ដោយបណ្ឌិតជាណេង។

**ហេង ដារី**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## ខែឧសភា ២០១១ អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ ដោយលោកបូជាចារ្យអ៊ុន សុន

### ថ្ងៃទី៨ ឧសភា អាទិត្យទី៣ នៃបុណ្យចម្លង (លូកា ២៤,១៣-៣៥)

ព្រះយេស៊ូបានចេញទៅសម្តែងធម្មទេសនា ព្រមទាំងថែរក្សា និងព្យាបាលអ្នកជំងឺនៅគ្រប់ទីកន្លែងក្នុងស្រុកយូដា អស់រយៈពេល ៣ ឆ្នាំ។ មានក្រុមសាវ័ក និងមនុស្សជាច្រើនមានជំនឿលើព្រះអង្គផង។ ព្រះយេស៊ូមានឈ្មោះល្បីនៅគ្រប់ទីកន្លែងដែលព្រះអង្គយាងទៅ។ ហេតុនេះហើយ នៅពេលព្រះអង្គសោយទីវង្គតនៅលើឈើឆ្កាង ធ្វើឱ្យប្រជាជនក្រុងយេរូសាឡឹមទាំងមូលចាប់អារម្មណ៍។

ក្រុមគ្រីស្តទូត និងពួកសាវ័ករបស់ព្រះអង្គ បាននាំគ្នាធ្វើសក្ខីភាពអំពីព្រះអង្គដែលសោយទីវង្គត និងមានព្រះជន្មរស់ឡើងវិញ។ ទោះបីពួកគេត្រូវជនជាតិយូដាប្រឆាំងធ្វើបាប និងរកសម្លាប់ក្តី ក៏ក្រុមសាវ័កមិនព្រមឈប់ប្រកាសអំពីព្រះអង្គឡើយ។

**តើខ្ញុំបានយកតម្រាប់តាមក្រុមសាវ័ក និងគ្រីស្តទូតប្រកាសថា : ព្រះយេស៊ូបានសោយទីវង្គត និងមានព្រះជន្មគង់នៅជាមួយខ្ញុំសព្វថ្ងៃនេះឬទេ?**

### *ថ្ងៃទី១៥ ឧសភា អាទិត្យទី៤ នៃបុណ្យចម្លង សប្តាហ៍នៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ (យ៉ូហាន ១,១-១០)*

**ទិវាអង្វរព្រះជាម្ចាស់ សូមឱ្យម្នាក់ៗទទួលស្គាល់ការត្រាស់ហៅរបស់ខ្លួន**

ការដើរតាមព្រះយេស៊ូ និងមានដំណើរជីវិតរួមជាមួយនិងព្រះអង្គក្នុងព្រះសហគមន៍គឺជាផ្លូវនៃសុភមង្គល។ សូមបងប្អូនជាគ្រីស្តបរិស័ទ យកពេលវេលាក្នុងសប្តាហ៍នៃការត្រាស់ហៅរបស់ព្រះជាម្ចាស់មករិះគិតពីជីវិតរបស់ខ្លួនម្នាក់ៗ មិនថា យើងជាមនុស្សចាស់-យុវជន ឬយើងជាកុមារឡើយ។ ការត្រាស់ហៅ គឺជាអំណោយទាន ដែលព្រះយេស៊ូប្រទានឱ្យ។ ព្រះអង្គបានមកស្វែងរកយើង ព្រមទាំងប្រទានអំណរសប្បាយដល់យើងទាំងអស់គ្នា។

ដរាបណាហ្វូងចៀមនៅជាមួយព្រះអង្គគឺមានសុវត្ថិភាពយ៉ាងពិតប្រាកដ។ ផ្ទុយទៅវិញបើហ្វូងចៀមណា ដែលបានបែកចេញពីហ្វូងពិតជាជួបនូវមហន្តរាយ។

**តើខ្ញុំបានយល់យ៉ាងណាអំពីការត្រាស់ហៅរបស់គង្វាលដ៏សប្បុរសចំពោះខ្ញុំ ?**

### ថ្ងៃទី២២ ឧសភា អាទិត្យទី៥ រដូវបុណ្យចម្លង (យ៉ូហាន ១៤,១-១២)

**"ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំជាផ្លូវ ជាសេចក្តីពិត និងជាជីវិត!"**

ព្រះជាម្ចាស់ដឹង និងជ្រាបនូវបញ្ហាដែលយើងមាន។ យើងតែងតែមានកង្វល់ជាច្រើនដូចជាផ្នែកសេដ្ឋកិច្ច(ថវិកា) កូនៗ អំពីអនាគត-ល-។

ខ្ញុំជាផ្លូវព្រះយេស៊ូបានប្រាប់យើងថា ក្នុងពេលវេលាពិបាកយ៉ាងណា ក៏ព្រះយេស៊ូធានាថា ព្រះអង្គគង់ជាមួយយើងគ្រប់ៗគ្នា។ ព្រះអង្គជាផ្លូវដែលនាំយើងទៅរកដំណាក់នៃព្រះបិតាដែលព្រះអង្គមានកន្លែងសម្រាប់យើងទាំងអស់គ្នា។ ខ្ញុំជាសេចក្តីពិត ដែលជាមូលដ្ឋានដែលចាំបាច់ក្នុងជីវិត។ ព្រះបន្ទូលជាសេចក្តីពិតដែលនាំឱ្យយើងចាកចេញពីកង្វល់ និងសេចក្តីអាក្រក់ទាំងឡាយ។ ខ្ញុំជាជីវិត ជីវិតដែលមានសេចក្តីសង្ឃឹម។ ឈើឆ្កាងមិនមែនជាទីបញ្ចប់នោះទេ ផ្ទុយនៅទទេ គឺមានការចាប់ផ្តើមនៃដំណាក់កាល និងមានជីវិតថ្មី។ **តើបងប្អូនបានសម្រេចចិត្តទទួលយកព្រះយេស៊ូធ្វើជាផ្លូវ ជាសេចក្តីពិត និងជាជីវិតឬទេ?**

### ថ្ងៃទី២៩ ឧសភា អាទិត្យទី៦ បុណ្យចម្លង *(យ៉ូហាន ១៤,១៥-២១)*

ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ គឺជាពេលវេលាដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយព្រះអង្គយាងទៅរកព្រះបិតា។ ព្រះយេស៊ូត្រូវការយើងស្រលាញ់ព្រះអង្គពិតប្រាកដដើម្បីឱ្យយើងចូលរួមធ្វើការសម្រាប់ព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលថា "ប្រសិនបើអ្នករាល់គ្នាស្រលាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ..." ខ្ញុំនឹងទូលអង្វរព្រះបិតាឱ្យទ្រង់ប្រទានព្រះជួយការពារមួយអង្គទៀតឱ្យគង់ជាមួយអ្នករាល់គ្នាជាដរាបទៅ"។ បើយើងស្រលាញ់ព្រះយេស៊ូ ព្រះជាម្ចាស់ក៏ស្រលាញ់យើងវិញដែរ ហើយព្រះបិតានឹងប្រទានព្រះវិញ្ញាណមកគង់ស្ថិតក្នុងយើង។ ការប្រតិបត្តិតាមព្រះយេស៊ូ គឺធ្វើឱ្យយើងមានចំណែកក្នុងព្រះជាម្ចាស់ដោយមានព្រះត្រៃឯក បានបញ្ជាក់ថា យើងនៅក្នុងព្រះបិតារបស់យើង អ្នករាល់គ្នាក្នុងយើង ហើយខ្ញុំស្ថិតក្នុងអ្នកលុះអវសាននៃពិភពលោក។ យើងជាគ្រីស្តបរិស័ទត្រូវទទួលស្គាល់ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ **តើខ្ញុំធ្វើអ្វីខ្លះដើម្បីបង្ហាញឱ្យដឹងថាខ្ញុំស្រលាញ់ព្រះយេស៊ូ?**



# យុវវ័យជួយស្ត្រីដូចជួយខ្លួនឯង និងសង្គមជាតិ (ត) *(បទពាក្យប្រាំពីរ)*



១១-ពាក្យយុវវ័យស្តីថែងថា
ចេះជួយសង្គ្រោះទោះតូចធំ
ចូលរួមស្នេហាក្នុងសង្គម
រឿងរ៉ាវជិតជុំកុំបង្កើត។

១២-បង្កហិង្សាដាក់អ្នកផ្សេង
មាក់ងាយគ្រួសារម្តាយបង្កើត
ធ្វើឫកសម្ញែងឯងដែផើត
អ្នកផ្តល់កំណើតកើតមានគុណ។

១៣-ឯចិត្តវិញពាលផ្សៀលបញ្ឆី
ទោសមានតិចស្រាលបណ្តាលធ្ងន់
ឆ្លើយឆ្លងដងខ្សឺព្រីពេកពន់
ទម្លាក់ទារុណដល់ញាតិមិត្ត។

១៤-ពេលខ្លះស្រវឹងប្រឹងជម្លោះ
បង្កជិតដាមស្នាមលោហិត
រករឿងកំហុសដែលប្រឌិត
ថាខ្លួនឯងពិតជាអ្នកត្រូវ។

១៥-ម៉ែឪប្រដៅហៅកូនស្ងួន
ត្រកូលសព្វជពង្សញាតិផៅ
គួរណាស់នឹមនួនដើរតាមផ្លូវ
កន្លងយូរទៅនូវកិត្តិនាម។

១៦-មានតែកេរ្តិ៍ឈ្មោះពីរោះស្តាប់
ចរិតឫកពារជាស្វាត់ស្មៀម
គ្មានទេចាក់កាប់បង្ហូរឈាម
គ្មានចិត្តលាក់លៀមចងគំនួច។

១៧-ពាក្យចាស់លោកថាកុំឱ្យអស់
ទោសធំសម្រាលស្រាលឱ្យរួច
ទោះតិចតួចសោះស៊ូឱ្យស្ងួច
ស៊ូសុំកុំលួចនាំធ្លាប់ដៃ។

១៨-បើកូនរក្សាមារយាទល្អ
ម៉ែឪបងប្អូនកូនទៀតក្តី
មនុស្សមានសីលធម៌ដ៏ប្រពៃ
ញាតិមិត្តប្រុសស្រីពោលសរសើរ។

១៩-ប្អូនយុវវ័យគួរគោរព
ប្រដៅណែនាំពាំបណ្តើរ
ពាក្យពេចន៍ល្អគាប់ជាប់ដំណើរ
រៀងរាល់សំណើរឪពុកម្តាយ។

២០-លោកខ្លាចក្រែងកូនដើរផ្លូវខុស
កូនមានឈាមជ័រកើតផ្ទៃម្តាយ
ពេលកូនមានទោសលោកសោកស្តាយ
ពាក្យម៉ែបរិយាយកូនគួរត្រាប់។

**និពន្ធដោយ :**
**លោកស្រី ឌុង ណារី**
**ថ្ងៃទី៧ មេសា ២០១១**
**រៀបរៀងដោយ :**
**លោក ឡុង សុជល**

# ពិធីហែស្លឹក និងសប្តាហ៍បុណ្យចម្លងនៅភូមិភាគភ្នំពេញ និងកំពង់ចាម

វណ្ណា សម្បតិ និងកញ្ញា



## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

## វិទ្យុវ៉េរីតាស់អាស៊ី (RVA)

**ភាសាខ្មែរផ្សាយរយៈពេល ៣០នាទី រាល់ថ្ងៃតាមរលកធាតុអាកាសខ្លី (sw) :**

ពេលល្ងាច ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្ដាប់វិទ្យុវ៉េរីតាស់ អាស៊ី (RVA)

លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃ និងសង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកនៅកម្ពុជា។

## កម្មវិធីវិទ្យុ អេម៉ានូអែល

អ្នកចូលរួមកម្មវិធីអេម៉ានូអែល “សម្លេងពីព្រះសហគមន៍កាតូលិក” ខែឧសភា

-ថ្ងៃអាទិត្យទី៨ ខែឧសភា ឆ្នាំ២០១១ អាទិត្យទី៣ នៃបុណ្យចម្លង : លោកបូជាចារ្យ ម៉ារីយ៉ូ ហ្គេស្សី ទទួលខុសត្រូវព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន រាជធានីភ្នំពេញ។

-ថ្ងៃអាទិត្យទី១៥ ខែឧសភា ឆ្នាំ២០១១ អាទិត្យទី៤ នៃបុណ្យចម្លង : ចូលរួមដោយលោកអភិបាលអេមីល ដេតម្ប៊។

-ថ្ងៃអាទិត្យទី២២ ខែឧសភា ឆ្នាំ២០១១ អាទិត្យទី៥ នៃបុណ្យចម្លង : ចូលរួមដោយលោកបូជាចារ្យឡាយ ប៉ូល ទទួលខុសត្រូវព្រះវិហារសន្តហ្វ្រង់ស្វ័រ សាវីយេ៉ (កអណ្ដើក) នៅឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។។

-ថ្ងៃអាទិត្យទី២៩ ឧសភា ឆ្នាំ២០១១ អាទិត្យទី៤ នៃបុណ្យចម្លង : បងស្រីសុជាតិ គ្រូអប់រំជំនឿនៅព្រះវិហារ សន្តបេណេឌីក នៅស្រុកកំពង់លាវ ខេត្តព្រៃវែង។

## កម្មវិធីវិទ្យុ “ខ្ញុំត្រូវការអ្នក”

ប្រធានបទសម្រាប់ខែឧសភា ឆ្នាំ២០១១ (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង ១០-១១ វេលាព្រឹក)

ថ្ងៃទី២ ឧសភា : យុវវ័យ និង Facebook។ ថ្ងៃទី៣ ឧសភា : យុវវ័យ ទីក្រុង និងជនបទ។ ថ្ងៃទី៩ ខែឧសភា : ការសម្រេចចិត្ត និងទំនួលខុសត្រូវ។ ថ្ងៃទី១០ ឧសភា : ការគ្រប់គ្រងវាសនាខ្លួនឯង។ ថ្ងៃទី១៦ ខែឧសភា : អាទិភាព។ ថ្ងៃទី១៧ ឧសភា : យុវវ័យ ឈ្នះ! ឈ្នះ!។ ថ្ងៃទី២៣ ខែឧសភា : មើលឱ្យជាក់ សឹមញាក់ចិញ្ចើម ! ថ្ងៃទី២៤ ខែឧសភា : យុវវ័យ និងកិច្ចសហប្រតិបត្តិការល្អ។ ថ្ងៃទី៣០ ខែឧសភា : សំលៀងទម្លាប់។ ថ្ងៃទី៣១ ខែឧសភា : យុវវ័យ និងក្ដីបសិក្សា។

សូមបញ្ជាក់ផងដែរថា ប្រធានបទទាំងនេះមានវាគ្មិនជំនាញរង់ចាំពិភាក្សាបកស្រាយ។

**សូមកុំភ្លេចតាមដាន!**

## ការងារប្រចាំខែ

- ថ្ងៃទី២ ខែឧសភា : ក្រុមបងស្រីមេត្តាករុណារៀបចំកម្មវិធីសំណាក់ធម៌ និងធ្វើការសម្រួលផ្លូវចិត្តក្នុងការបម្រើព្រះសហគមន៍នៅព្រះសហគមន៍កាតូលិកសៀមរាប។
- ថ្ងៃទី៧-៨ ខែឧសភា : សិក្ខាសាលាយុវជន-យុវនារី ក្រោមប្រធានបទ “គ្រីស្តបរិស័ទមានសកម្មភាពយ៉ាងពិតប្រាកដក្នុងជីវិតប្រចាំថ្ងៃ” ដែលត្រូវបានរៀបចំធ្វើឡើងនៅព្រះសហគមន៍កំពតកាតូលិក។
- ថ្ងៃទី១៣-១៥ ខែឧសភា : ព្រះសហគមន៍កាតូលិកកំពង់ចាមមានរៀបចំកម្មវិធីបូជនីយចរដោយជិះកង ពីកំពង់ចាមទៅភ្នំមិថ្នពេជ្រ ពីថ្មភ្នំមិថ្នពេជ្រទៅសួង ពីសួងទៅចម្លាក់ ពីចម្លាក់ទៅអូររាំងឪ និងពីអូររាំងឪមកកំពង់ចាមវិញ។ កម្មវិធីបូជនីយចរនេះធ្វើឡើងក្រោមប្រធានបទ “កុំខ្មាស់អៀនក្នុងការប្រកាសជំនឿរបស់ខ្លួនទៅអ្នកដទៃក្នុងអង្គព្រះយេស៊ូ”។
- ថ្ងៃទី១៣-១៤-១៥ ខែឧសភា : ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី។
- ថ្ងៃទី១៤-១៥ ឧសភា : ក្រុមអេម៉ាណូអែល និងសាម៉ូអែលបានរៀបចំកម្មវិធីទិវានៃការត្រាស់ហៅសម្រាប់យុវជនយុវនារី ក្រោមប្រធានបទ “រិះគិតអំពីការត្រាស់ហៅ” នៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី២១ ខែឧសភា : ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល។
- ថ្ងៃទី២១-២២ ខែឧសភា : សិក្ខាសាលាយុវជន-យុវនារី ក្រោមប្រធានបទ “គ្រីស្តបរិស័ទមាន សកម្មភាពយ៉ាងពិតប្រាកដក្នុងជីវិតប្រចាំថ្ងៃ” រៀបចំធ្វើឡើងនៅព្រះសហគមន៍កាតូលិកតាកែវ។


**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរវ៉ជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧